# WHY BUDDHISM?
# ហេតុអ្វីបានជាមានពុទ្ធសាសនា?

By Venerable Dr. K Sri Dhammananda
Translated by Bhikkhu Suy Sovann (Pannavaro)

## THE AIM OF BUDDHISM

## គោលបំណងពុទ្ធសាសនា

Freed am I, O Bhikkhus, from all bonds, whether divine or human. You, too, O Bhikkhus, are freed from all bonds whether divine or human.

ម្នាលភិក្ខុទាំងឡាយ តថាគតបានរួចផុតពីចំណងទាំងឡាយ មិនថាទេវតា ឬមនុស្ស។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយក៏គួរតែរួចផុតពីចំណងទាំងឡាយ មិនថាទេវតា ឬមនុស្ស ។

"Go forth, O Bhikkhus, for the good of the many, for the happiness of the many, out of compassion for the world, for the good, benefit, and happiness of gods and men… Let not two go by one way. Preach, O Bhikkhus, the Dhamma, excellent in the beginning, excellent in the middle, excellent in the end, both in spirit and in the letter. Proclaim the Holy Life altogether, perfect and pure".

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរត្រាច់ទៅកាន់ចារិកគឺ ស្រុក និគម និងរាជធានី ហើយសំដែងធម៌ ដើម្បីជាប្រយោជន៏ និងសេចក្តីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៏ ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ។ អ្នកទាំងឡាយ កុំគប្បីទៅពីរនាក់តាមផ្លូវតែមួយឡើយ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសំដែងធម៌ឱ្យពីរោះ បទខាងដើម បទកណ្តាល និងបទចុង ទាំងមានលំអក្នុងអត្ថ និងព្យញ្ជនៈ ។ អ្នកទាំងឡាយ ចូរធ្វើជីវិតឱ្យបរិសុទ្ធ ឧត្តុង្គឧត្តម និងល្អប្រពៃ ។

"There are beings with a little dust in their eyes, who, not hearing the Dhamma, will fall away. There will be those who understand the Dhamma".

(The Buddha..)

សត្វលោកទាំងឡាយដែលមានធូលី (កិលេស) តិចតួចនៅក្នុងភ្នែកនឹងអាចស្តាប់ឮព្រះធម៌ ព្រមទាំងអាចយល់នូវព្រះធម៌ មានដោយពិត ។

**ព្រះសម្មាសម្ពុទ្ធ**

## FOUNDATION OF RELIGIONS
## កំណើតសាសនា

Before we discuss this subject " Why Buddhism?". We must find out why religion or how the idea of religion started in man's mind at the beginning.

មុននឹងយើងពិភាក្សាពីប្រធានបទថា "ហេតុអ្វីបានជាមានព្រះពុទ្ធសាសនា?" នេះ យើងត្រូវតែឈ្វេងយល់ថា ហេតុអ្វីត្រូវមានសាសនា? ឬថា តើដំបូងទស្សនៈសាសនាបានចាប់ផ្ដើមដុះឡើងក្នុងសន្ដានចិត្តរបស់មនុស្សដូចម្ដេច?

Thousands of years ago when man's mind started thinking about various kinds of natural phenomena in this world, he found many wonderful experiences. When certain natural forces or phenomena were not in his favour he had to suffer. He had seen disasters, and terrific incidents. Then he started to think of how to find out a solution to get rid of unfavourable conditions which created fear, suspicion, insecurity, tension and suffering. He knew that these things were beyond the comprehension of man's thinking power.

រាប់ពាន់ឆ្នាំកន្លងទៅហើយ ដែលចិត្តរបស់មនុស្សលោកបានចាប់ផ្ដើមសញ្ជឹងគិតលើបាតុភូតធម្មជាតិប្លែកៗនៅក្នុងពិភពលោកនេះ គេបានស្វែងរកការពិសោធដ៏អស្ចារ្យជាច្រើនលើកច្រើនសា។ ពេលមានឥទ្ធិពលធម្មជាតិ ឬបាតុភូតធម្មជាតិមិនជាទីពេញចិត្តកើតឡើងចំពោះគេ គេក៏កើតទុក្ខមិនសុខចិត្ត។ ពួកគេបានឃើញ ឬជួបប្រទះនឹងគ្រោះមហន្តរាយ និងឧបទ្ទវហេតុដ៏គួរឱ្យរន្ធត់។ បន្ទាប់មក គេបានចាប់ផ្ដើមគិតរកវិធីដោះស្រាយយ៉ាងណា ដើម្បីកំចាត់ចោលនូវល័ក្ខខ័ណ្ឌមិនជាទីពេញចិត្ត ដែលបានធ្វើឱ្យមាន ការភ័យខ្លាច ការសង្ស័យ អសន្តិសុខ ការញាប់ញ័ររន្ធត់ និងសេចក្ដីទុក្ខទាំងពួង ។ ពួកគេដឹងថា វត្ថុទាំងនោះខ្ពស់ហួសពីសមត្ថភាពគិតរបស់មនុស្ស។

Therefore, he thought there must be some invisible powerful supernatural forces or persons behind all these things. Then he started to pray and worship them and started to make animal sacrifices in order to please these supernatural powers. He also started to praise and worship as thanksgiving when certain phenomena were in his favour by thinking that these were the acts of gods.

ដូច្នេះពួកគេបានគិតថា ប្រាកដជាមានវត្ថុស័ក្ដិសិទ្ធ ឬមនុស្សមានមហិទ្ធិឫទ្ធិអស្ចារ្យណាមួយនៅខាងក្រោយវត្ថុទាំងនោះ ដែលពួកគេមិនអាចមើលឃើញ។ ក្រោយមក ពួកគេបានចាប់ផ្ដើមសំបូងសង្រួងបួងសួងបន់ស្រន់ និងបូជាដោយសត្វពាហនៈទាំងឡាយ ដើម្បីផ្គាប់ផ្គុនដល់វត្ថុស័ក្ដិសិទ្ធទាំងឡាយនោះ។ ពួកគេបានបន់ស្រន់ និងគោរពបូជាទុកជាការថ្លែងអំណរគុណ នៅពេលដែលវត្ថុទាំងឡាយបានជាទីពេញហឫទ័យរបស់គេ ដោយពួកគេគិតថាជាទង្វើរបស់ព្រះអាទិទេព។

The aim of these practices is to gain protection and blessing from these gods to live in this world without facing much difficulties. That was how this belief or practice called religion originated. That was why man started to develop, certain other important practices were also incorporated into religion. They were religious rites, rituals, and ceremonies or festivals. They organised them according to their traditions, customs, and ways of life in their own respective countries.

គោលបំណងនៃការប្រតិបត្តិគោរពបូជានេះ ក្នុងបំណងចង់ទទួលបាននូវការថែរក្សាការពារ និងឱ្យពរជ័យសិរីសួស្ដីពីព្រះអាទិទេព ដើម្បីរស់នៅប្រកបដោយសេចក្ដីសុខសប្បាយក្នុងលោកនេះ។ ជំនឿ ឬការប្រតិបត្តិបែបនេះហើយ ដែលបណ្ដាលឱ្យមានការកកើតសាសនាដំបូងបង្អស់។ នោះក៏ជាបុព្វហេតុដែលមនុស្សទាំងឡាយបានចាប់ផ្ដើមគោរពបូជាបន់ស្រន់ចំពោះវត្ថុស័ក្ដិសិទ្ធិក្នុងលោក។ ពេលទស្សនៈសាសនានេះ បានចាប់ផ្ដើមរីកចំរើនរុងរឿងឡើង ការគោរពប្រតិបត្តិបូជា ចំពោះវត្ថុសំខាន់ៗទាំងឡាយក៏ស្ថិតនៅក្នុងសាសនាផងដែរ។ ពិធីទាំងអស់នោះ មានដូចជាពិធីសិវៈរាត្រី ការបួងសួងបន់ស្រន់ និងពិធីបុណ្យផ្សេងៗ។ ពួកគេបានរៀបចំចាត់ចែងកម្មវិធីបុណ្យទាំងឡាយ

ទាំងពួងស្របតាមទំនៀមទំលាប់ប្រពៃណីរបស់ពួកគេ និងស្របតាមរបៀបរបបរស់នៅជាក់ស្តែង ក្នុងប្រទេសរបស់គេរៀងៗខ្លួន ។

The foundation of religion was laid by man at the beginning for self-preservation because of fear, suspicion, insecurity, misunderstanding of life and natural phenomena. These served as the foundation for religions as materials like bricks, stones, sand, cement and earth used for laying the foundation of a building.

កំណើតសាសនា ឬប្រភពនៃការកកើតសាសនាដំបូងបង្អស់ ត្រូវបានបង្កើតឡើងដោយមនុស្សជាតិ សម្រាប់ការពារខ្លួនពីសេចក្តីភ័យខ្លាច សេចក្តីសង្ស័យ អសន្តិសុខ អសីលធម៌ និងបាតុភូតធម្មជាតិទាំងឡាយ។ ទាំងនេះជាប្រភពនាំឱ្យកើតសាសនា ប្រៀបបីដូចជាសម្ភារៈទាំងឡាយ មានក្បឿង ថ្ម ដីខ្សាច់ ស៊ីម៉ងត៍ និងដី ដែលត្រូវបានគេប្រើប្រាស់សម្រាប់ចាក់គ្រឹះអាគារ ដូច្នោះដែរ ។

After that, man erected this building of religion by introducing faith, offerings, prayers, vows, penalties, morals and ethics in the name of god in order to control mankind. And also to find out an eternal place called paradise for one’s happiness and peace of the soul.

បន្ទាប់មកទៀត មនុស្សបានកសាងអាគារ ពោលគឺមូលដ្ឋានគ្រឹះសាសនានេះ ដោយពន្យល់ណែនាំពីសទ្ធា ការឱ្យទាន ការបួងសួងបន់ស្រន់ ការទទួលទណ្ឌកម្ម និងក្រមសីលធម៌មានក្នុងនាមព្រះអាទិទេព ដើម្បីឃុំគ្រងមនុស្សជាតិ។ ហើយនឹងស្វែងរកនូវកន្លែងអមតៈ ដែលគេហៅថា "ឋានសួគ៌" សម្រាប់សេចក្តីសុខ សុភមង្គល និងសេចក្តីសុខស្ងប់នៃព្រលឹងវិញ្ញាណរបស់មនុស្ស ។

## FOUNDATION OF BUDDHISM

## កំណើតពុទ្ធសាសនា

Later, when we study how another religion called “Buddhism” came into existence, we find that Buddha had not used any of those age old beliefs. He did not introduce the concept of god, soul theory, eternal hell or eternal heaven to build up Buddhism. He did not make use of fear and distorted views regarding the natural phenomena in support of his religion.

ក្រោយមក ពេលយើងសិក្សារៀនសូត្រនូវរបៀបវិធីសាសនាមួយផ្សេងទៀត ដែលត្រូវបានគេហៅថា "ពុទ្ធសាសនា" កើតឡើងក្នុងលោក យើងយល់ថា ព្រះសម្មាសម្ពុទ្ធមិនបានប្រើនូវជំនឿចាស់ទាំងនោះឡើយ។ ព្រះអង្គមិនបានយកទស្សនៈអាទិទេព ទ្រឹស្តីព្រលឹងវិញ្ញាណ នរកអមតៈ សគ្គាមតៈ ក្នុងការបង្កើតពុទ្ធសាសនាឡើយ។ ព្រះអង្គមិនបានប្រើទស្សនៈបំភិតបំភ័យ និងទស្សនៈគាបសង្កត់ (បង្ខិតបង្ខំ) ដែលចាត់ថា ជាបាតុភូតធម្មជាតិ ដើម្បីទ្រទ្រង់សាសនារបស់ព្រះអង្គក៏ទេដែរ។

Neither did he ask for blind faith or unnecessary rites and rituals. He did not believe in self-torture, nor the imposition of penalties or commandments in the building up of Buddhism. He also did not seek for any message from elsewhere to build up Buddhism.

ព្រះអង្គថែមទាំងមិនអំពាវនាវ (អង្វរករ) ឱ្យជឿទាំងងងឹតងងុល ឬក៏ធ្វើនូវការគោរពបូជាដែលគ្មានប្រយោជន៏ដែរ។ ព្រះអង្គមិនជឿក្នុងការដាក់ទារុណកម្មខ្លួនឯង ទាំងមិនជឿក្នុងការដាក់ពិន័យឱ្យទទួលយក ឬការបង្គាប់បញ្ជាក្នុងការបង្កើតព្រះពុទ្ធសាសនាឡើយ។ ព្រះអង្គក៏មិនបានស្វែងរកឯកសារណាមួយ ពីកន្លែងផ្សេងទៀត ក្នុងការបង្កើតពុទ្ធសាសនា។

He used different idea or materials such as Right Understanding of the life, the world and the natural phenomena or cosmic order and the real characteristics of mind and matter, elements and energies, moral and spiritual development, discipline, mental training and purification, knowledge, wisdom and enlightenment to erect this religious building.

ព្រះអង្គបានប្រើទស្សនៈ ឬសម្ភារៈទាំងឡាយ មានដូចជាការយល់ឃើញត្រូវ (សម្មាទិដ្ឋិ) នៃជីវិត ពិភពលោក និងបាតុភូតធម្មជាតិ ឬអំណាចនៃចក្កវាឡ និងលក្ខណៈពិតនៃនាមរូប ធាតុទាំងឡាយ ឫទ្ធិ (ថាមពល) សីលសិក្ខាវិន័យ វិបស្សនា និងវិសុទ្ធិ ចំណេះដឹង បញ្ញា និងការត្រាស់ដឹងនូវសច្ចធម៌ ក្នុងការបង្កើតភូមិគ្រឹះ ពោលគឺសាសនានេះ។

It is true that he used certain religious materials used by other religionists at that time such as kamma– action and reaction, rebirth and certain moral principles but not in the same manner or in the same sense. He refined them and  introduced them in a rational, scientific and psychological way.

ពិតណាស់ដែលថា ព្រះដ៏មានព្រះភាគបានប្រើនូវសម្ភារៈនៃសាសនាពិតប្រាកដ ដែលត្រូវបានមេពាហិរសាសនាទាំងឡាយប្រើនៅសម័យកាលនោះ មានដូចជា កម្មផល បដិសន្ធិ និងក្រមសីលធម៌ពិត ប៉ុន្តែមិនស្ថិតក្នុងលក្ខណៈដដែល ឬក៏ន័យដូចគ្នាទេ ។ ព្រះអង្គបានចម្រាញ់នូវទស្សនៈទាំងនោះ និងទ្រង់ត្រាស់សំដែងទុកមក តាមសមគួរដល់ហេតុផល ជាលក្ខណៈវិទ្យាសាស្ត្រ និងចិត្តសាស្ត្រវិញ។

## AN INDEPENDENT RELIGION

## សាសនាឯករាជ្យ

Buddhism is not a concoction of religions. It had its own characteristics and identity. By realising that no other religious teachers had found the absolute truth and final salvation of man, he pointed out that others had developed only certain worldly powers and could manage to attain only certain stages of spiritual development without complete purification of the mind, and also not free from all superstitious beliefs, impurities, illusion, delusion, imagination, hallucination and ignorance.

ព្រះពុទ្ធសាសនាមិនមែនជាសាសនាច្របូកច្របល់ឡើយ។ សាសនានេះមានលក្ខណៈ និងភិនភាគសំគាល់ផ្ទាល់ខ្លួនជាក់លាក់។ ដោយដឹងថា គ្មានគ្រូពាហិរសាសនាណា បានរកឃើញនូវសច្ចធម៌ និងទីបំផុតទុក្ខរបស់មនុស្សលោក ដូច្នេះព្រះសម្មាសម្ពុទ្ធបានចង្អុលបង្ហាញថា មេពាហិរសាសនាទាំងឡាយចម្រើនសម្រេចបានត្រឹមតែលោកិយឈាន និងសមាបត្តិប៉ុណ្ណោះ ដោយមិនអាចជម្រះនូវសន្តានចិត្តឱ្យស្អាតបរិសុទ្ធបាន ហើយក៏មិនអាចគេចផុតពីជំនឿអរូបី និងសេចក្តីសៅហ្មង (កិលេស) ជំនឿខុស សេចក្តីវង្វេង (មោហៈ) ការស្រមើស្រមៃ ភាពស្រពេចស្រពិល និងភាពអវិជ្ជាបានឡើយ។

The real meaning or the purpose of this word “religion” can be understood when we study the way how the Buddha introduced this “religious way of noble life.” If we were to utilise the word “religion” to introduce the teachings of the Buddha, we must also understand the different interpretations given this word by other religionists, then everyone can understand “Why Buddhism” is needed.

ខ្លឹមសារពិត ឬគោលដៅពិតនៃពាក្យ "សាសនា" អាចត្រូវបានយល់ច្បាស់នៅពេលគេសិក្សាអំពីរបៀប ឬវិធីដែលព្រះអង្គទ្រង់សំដែងអំពីអរិយសច្ចធម៌ (អរិយមគ្គ ឬអរិយបុគ្គល) នេះ។ ប្រសិនបើយើងយកពាក្យ "សាសនា" មកប្រើក្នុងការពន្យល់ណែនាំអំពីទ្រឹស្តីព្រះពុទ្ធ (ពុទ្ធវចនៈ) យើងត្រូវតែយល់នូវការបកស្រាយផ្សេងៗ ដែលមេពាហិរសាសនាទាំងឡាយកំណត់ឱ្យ។ ពេលនោះយើងទាំងអស់គ្នាប្រាកដជាយល់បានថា ហេតុអ្វីបានគេត្រូវការព្រះពុទ្ធសាសនា នុ៎ះហើយ ។

## NO DOGMAS

## គ្មានជំនឿខាប់គ្រូឡា

The Buddha managed to remove certain misconceptions, which had been held by people for thousands of years. For example, in those days everybody in this world believed that the sun rotated daily round the earth. People had this belief due to lack of proper knowledge of the world system. But when Copernicus discovered and proved that it is not the sun that rotate round the earth but is this earth which goes around the sun, then slowly people realised that it is true.

ព្រះសម្មាសម្ពុទ្ធ បានលុបបំបាត់នូវការប្រកាន់ខុស (អបិយជំនឿ) ដែលត្រូវបានបង្កើតដោយមនុស្សទាំងឡាយអស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ។ ឧទាហរណ៍ នៅសម័យដើម មនុស្សនៅក្នុងពិភពលោកនេះយល់ថា ព្រះអាទិត្យវិលជុំវិញផែនដីជារៀងរាល់ថ្ងៃ។ មនុស្សទាំងឡាយមានជំនឿបែបនេះ ដោយសារតែខ្វះចំណេះដឹងខាងប្រព័ន្ធពិភពលោក (ផែនដី)។ ប៉ុន្តែនៅពេលលោក ***កូពើនីកូស*** (Copernicus) ស្រាវជ្រាវរាវរកឃើញ និងបញ្ជាក់ថា មិនមែនព្រះអាទិត្យទេ ដែលវិលជុំវិញផែនដី ពោលគឺផែនដីនេះទេតើដែលវិលជុំវិញព្រះអាទិត្យ ។ ពេលនោះ មនុស្សទាំងឡាយបានទទួលស្គាល់ថាត្រឹមត្រូវ។

There was another misconception people had about the earth. For thousands of years people believed that the earth was flat. Galileo discovered and proved that the earth is round but not flat. Later people accepted that truth also.

មានការយល់ឃើញខុសគ្នា (ប្រកាន់ខុស) មួយផ្សេងទៀត អំពីផែនដី។ រាប់ពាន់ឆ្នាំកន្លងទៅហើយ ដែលមនុស្សយល់ (មានជំនឿ)ថា ផែនដីមានរាងសំប៉ែត។ លោក ***ហ្គាលីឡេវ*** (Galileo) បានស្រាវជ្រាវរាវរកឃើញ និងប្រកាស (បញ្ជាក់) ថា ផែនដីមានរាងមូល មិនមែនសំប៉ែតទេ។ ក្រោយមក មនុស្សបានទទួលយកថា នោះជាការពិតផងដែរ។

When Copernicus discovered that the sun is the centre of our solar system, people had to give up the former belief that the earth is the centre of our solar system. The belief that many ancient philosophers had up to the19th Century that the atom is the ultimate entity of matter,

and that it is impossible to split it, was given up when nuclear scientists managed to split it; likewise the belief that the people had for thousands of years that the soul is a permanent entity created by God had to be given up when the Buddha pointed out and gave his reasons that it is a wrong concept and there is no such thing as permanent entity. To him it is only a dream.

នៅពេលលោក ***កូភើនិកូស*** (Copernicus) បានស្រាវជ្រាវរាវរកឃើញថា ព្រះអាទិត្យស្ថិតនៅក្នុងមណ្ឌលនៃប្រព័ន្ធសុរិយគតិរបស់យើង មនុស្សទាំងឡាយក៏បានបោះចោលនូវជំនឿដែលថា ផែនដីស្ថិតនៅក្នុងមណ្ឌលនៃប្រព័ន្ធសុរិយគតិរបស់យើង។ ជំនឿដែលបុរាណទស្សនវិទូទាំងឡាយបានបង្កើតនៅសតវត្សទី១៩ ថា អាតូមគឺជាបរមត្ថរូប ហើយវាមិនអាចបំបែកចេញពីគ្នាបាន ក៏ត្រូវបានគេបោះបង់ចោល នៅពេលអ្នកវិទ្យាសាស្ត្រ ***នុយក្លេអ៊ែរ*** (Nuclear) អាចញែកឱ្យនៅដាច់ពីគ្នាបាន។ ស្រដៀងគ្នានេះដែរ ជំនឿមួយដែលមនុស្សប្រកាន់យកអស់រយៈពេលរាប់ពាន់ឆ្នាំហើយថា អត្តាពោលគឺតួខ្លួន ឬវិញ្ញាណជាវត្ថុអមតៈ ដែលបានបង្កើតឡើងដោយព្រះអាទិទេព ក៏ត្រូវបានគេបោះបង់ចោល នៅពេលព្រះសម្មាសម្ពុទ្ធបានទ្រង់ត្រាស់សំដែង និងផ្តល់ហេតុផលរបស់ព្រះអង្គថា វាជាការប្រកាន់ទស្សនៈខុស ហើយព្រះអង្គសំដែងថា គ្មានវត្ថុអ្វីជាអមតៈឡើយ។ ចំពោះព្រះពុទ្ធអង្គវិញ ព្រះអង្គប្រៀបធៀបករណីនេះថា ហាក់បីដូចជាការយល់សប្តិប៉ុណ្ណោះ។

This belief exists in man’s mind just like the visual object of rainbow colours where there is no reality. The Buddha explained that the idea of soul is only a misunderstanding of man’s consciousness. If there is a soul, is there any reason for the Buddha to hide it without revealing it to His followers? Certainly no, particularly because this concept of soul theory is a very important issue to every other religionist.

ជំនឿនេះបានដក់ជាប់ក្នុងដួងចិត្តមនុស្សលោក បីដូចជាពណ៌ឥន្ទធនូដែលមើលឃើញដោយចក្ខុ គ្មានកន្លែងណាមួយពិតសោះ។ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា អត្តទស្សនៈគឺជាទស្សនៈមិច្ឆាទិដ្ឋិពេញទី។ ចុះប្រសិនបើមានអត្តៈមែន តើមានហេតុផលណាមួយចំពោះព្រះសម្មាសម្ពុទ្ធក្នុងការលាក់វា ដោយមិនសំដែងប្រាប់ដល់សាវ័ករបស់ព្រះអង្គទៅ? តាមសច្ចភាព វាពិតជាគ្មានទេ តែដោយសារអត្តទស្សនៈគឺជាបញ្ហាមួយដ៏សំខាន់បំផុត ចំពោះមេដឹកនាំពាហិរ-សាសនាទាំងឡាយ។

The theory of evolution, which was discovered by Charles Darwin, disproved the then popular creation theory that life was created by God. Geology, Biology and Physiology also explained very clearly that it had taken million of years for the the appearance of first life on this earth. These discoveries never contradict each other when one studies the teachings of the Buddha very carefully. Modern discovery of the gradual development of mineral life, plant life and other living things and living beings coincided with the teachings of the Buddha.

អនិច្ចទស្សនៈ ដែលត្រូវបានរកឃើញដោយលោក ***ឆាលឡេស ដាវិន*** (Charles Darwin) មិនទាន់បានប្រកាសឡើងផង ការបង្កើតទ្រឹស្តីប្រជាប្រិយមួយដែលថា ជីវិតត្រូវបានបង្កើតដោយព្រះអាទិទេព ក៏លេចចេញមក។ ភូគម្ព-សាស្ត្រក្តី ជីវសាស្ត្រក្តី និងរូបសាស្ត្រក្តីបានពន្យល់យ៉ាងច្បាស់ថា វាមានរយៈពេលរាប់លានឆ្នាំមកហើយ ដែលមានភាវៈមានជីវិតដំបូងបង្អស់នៅលើផែនដីនេះ។ របកគំហើញទាំងនេះ មិនផ្ទុយគ្នាទេ នៅពេលយើងសិក្សារៀនសូត្រអំពីពុទ្ធវចនៈ ពោលគឺពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធឱ្យបានល្អិតល្អន់ច្បាស់លាស់នោះ។ ការស្រាវជ្រាវរាវរកពីជីវិតរ៉ែក្តី ជីវិតរុក្ខជាតិក្តី ជីវិតសត្វក្តី និងជីវិតមនុស្សក្តី នៅក្នុងសម័យទំនើបនេះ ក៏បានធ្វើដំណើរស្របគ្នាទៅនឹងទ្រឹស្តីពុទ្ធសាសនា បន្តិចម្តងៗហើយដែរ។

To the question how life came into existence, the Buddha gave a simple and reasonable answer. He said life is only a combination of mind and matter. Further he defined the mind as

composed of feeling, perception, mental formations and consciousness again he analysed the matter into for elements as solidity, fluidity, heat and motion.

ត្រង់បញ្ហាថា តើជីវិតកើតមកនៅលើផែនដីនេះ ដោយរបៀបណា? ព្រះសម្មាសម្ពុទ្ធបានផ្តល់នូវចំលើយដ៏សាមញ្ញ និងសមហេតុសមផលបំផុត។ ព្រះអង្គទ្រង់ត្រាស់សំដែងថា ជីវិតគឺជាការប្រមូលផ្តុំ ឬផ្សំគ្នា នៃ**នាម** និង***រូប*** ។ ជាងនេះទៅទៀត ព្រះអង្គទ្រង់ពន្យល់ថា "**នាម**"ត្រូវបានតាក់តែងចងក្រងឡើងដោយ ***វេទនា សញ្ញា សង្ខារ*** និង***វិញ្ញាណ*** ។ ម្យ៉ាងទៀត ព្រះអង្គបានវិភាគវែកញែក "***រូប***" ទៅនឹងធាតុទាំងឡាយបួន មាន: **ធាតុដី ធាតុទឹក ធាតុភ្លើង** និង **ធាតុខ្យល់** ។

When we study the explanation of the Buddha about the cosmos, we find that he mentioned the existence of certain living beings, both fortunate and unfortunate, not only in this world but also in certain other planets.

នៅពេលយើងរៀនសូត្រនូវសេចក្តីពន្យល់របស់ព្រះសម្មាសម្ពុទ្ធស្តីអំពីលោកធាតុ យើងយល់ថា ព្រះអង្គបានអធិប្បាយអំពីសត្វលោកពិត១ ទាំងមានសំណាង និងគ្មានសំណាង ។ មិនត្រឹមតែក្នុងលោកនេះប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គក៏ទ្រង់សំដែងអំពីភពផ្សេង១ទៀតផងដែរ ។

The modern scientists and astronomers are open mined and conceded the possibility of the existence of some living beings in certain other planets.

អ្នកវិទ្យាសាស្រ្ត និងតារាវិទូសម័យទំនើបបានបន្ទាបខ្លួន និងទទួលស្គាល់នូវសមត្ថភាពរបស់សព្វសត្វមួយចំនួនដែលរស់នៅក្នុងភពដទៃទៀត ។

Many of those traditional religious beliefs are exactly like the former beliefs about the world system and the origin of life. But the Buddha’s teachings are akin to the new discoveries.

ជំនឿប្រពៃណីសាសនាទាំងឡាយ គឺពិតជាដូចគ្នានឹងជំនឿ កាលពីអតីតកាល ដែលស្តីពីប្រព័ន្ធពិភពលោក (ផែនដី) និងដើមកំណើតជីវិតលើផែនដី (ការកកើត) អញ្ចឹងដែរ ។ ប៉ុន្តែតាមពុទ្ធវចនៈ គឺប្រហាក់ប្រហែលនឹងរបកគំហើញថ្មីនេះ។

The belief that religious rites and rituals were the only important practices for man to find his salvation was not supported by the Buddha. According to the Buddha the development of morality, concentration or the purification of mind are the important aspects of religious life for the final salvation.

ទស្សនៈដែលពាហិរសាសនាទាំងឡាយចាត់ទុកថា ជាការប្រតិបត្តិដ៏មានប្រយោជន៍បំផុត ចំពោះមនុស្សក្នុងការស្វែងរកទីពឹងរបស់ខ្លួន (ការការពារ) មិនត្រូវបានគាំទ្រដោយព្រះសម្មាសម្ពុទ្ធទេ។ ផ្អែកតាមព្រះសម្ពុទ្ធ ការរក្សាសីល ការចម្រើនសមាធិ ឬការជម្រះចិត្តឱ្យស្អាតចាកគ្រឿងសៅហ្មងទាំងឡាយ គឺជាទស្សនវិស័យល្អបំផុតរបស់សាសនា ក្នុងការដល់ទីបំផុតទុក្ខ (ទីរំលត់ទុក្ខ) ។

He pointed out that for a man to be religious; he must lead a harmless, blameless, respectable, decent, noble, and pure life. The mere act of praying or making offering does not by itself make a man a religious man or gain him his perfection and salvation.

ព្រះអង្គបានចង្អុលបង្ហាញថា មនុស្សជាអ្នកមានសាសនា ពួកគេត្រូវតែដឹកនាំជីវិតដោយគ្មានការបៀតបៀន គ្មានការទិតៀននិន្ទា ជាមនុស្សគួរឱ្យគោរព មានសុជីវធម៌ល្អប្រពៃ និងបរិសុទ្ធស្អាត ។ ការបួងសួង ឬការបូជា មិនមែនញុំាងមនុស្សឱ្យក្លាយជាសាសនិក ឬក៏សម្រេចបាននូវសេចក្តីបរិសុទ្ធ និងការរួចចាកទុក្ខឡើយ ។

He also advised people to keep away from evil practices. The idea of keeping away from evil must be for the welfare of the living beings and not because of the fear of god or punishment. At the same time, he advised us to cultivate the good humane qualities, practise good deeds, and help others without any selfish motive.

ព្រះសម្មាសម្ពុទ្ធ បានទូន្មានប្រៀនប្រដៅមនុស្សមិនឱ្យធ្វើអំពើបាបទាំងឡាយទាំងពួង។ ទស្សនៈនៃការមិនឱ្យធ្វើនូវអំពើបាបនេះ ត្រូវតែជាកាតព្វកិច្ចរបស់មនុស្សទាំងអស់គ្នា ហើយមិនមែនដោយសារការខ្លាចព្រះអាទិទេព ឬទណ្ឌកម្មនោះទេ។ ទន្ទឹមនឹងនេះ ព្រះអង្គបានទូន្មានយើងទាំងអស់គ្នាឱ្យចម្រើនមេត្តាធម៌ ធ្វើតែអំពើល្អ និងជួយសង្គ្រោះអ្នកដទៃ ដោយមិនគិតតែពីប្រយោជន៍ខ្លួន។

The Buddha was the only religious teacher who gave highest credit to man’s intelligence. He advised us not to become slaves to external agencies but to develop our hidden power with self-confidence.

ព្រះសម្មាសម្ពុទ្ធ គឺជាមេដឹកនាំសាសនាតែមួយគត់ ដែលបានផ្តល់នូវកិត្តិស័ព្ទ កិត្តិគុណ ដល់មនុស្សលោកទាំងឡាយ ។ ព្រះអង្គបានប្រៀនប្រដៅយើង មិនឱ្យក្លាយខ្លួនជាទាសៈរបស់ពាហិរសាសនា ប៉ុន្តែព្រះអង្គ បានឱ្យយើងពង្រឹងនូវសមត្ថភាព ដែលមានក្នុងខ្លួនរបស់យើង ឱ្យមានភាពជឿជាក់លើខ្លួនឯងឡើង ។

He also pointed out that man is responsible for everything in this world. His pain and pleasure, both were created by him and he has the ability to get rid of his sufferings and maintain peace and happiness by using his effort and wisdom without depending on external powers. Man’s untrained mind is responsible for all the troubles, calamities, disturbances, unfavourable atmosphere and the changes of elements and matter.

ព្រះអង្គបានសំដែងទៀតថា មនុស្សគឺត្រូវតែទទួលខុសត្រូវចំពោះអ្វីៗក្នុងលោកនេះ សេចក្តីទុក្ខក្តី សេចក្តីសុខក្តី កើតមានព្រោះមនុស្សជាអ្នកបង្កើត ហើយមនុស្សត្រូវតែមានសមត្ថភាពក្នុងការគេចចេញពីសេចក្តីទុក្ខ និងរក្សានូវសន្តិភាព សុភមង្គល ដោយអំណាចនៃសេចក្តីព្យាយាមប្រឹងប្រែងដោះស្រាយបញ្ហារបស់ខ្លួន មិនចាំបាច់ពឹងផ្អែកលើព្រះអាទិទេពណាមួយឡើយ ។ ចិត្តដែលមិនបានអប់រំរបស់មនុស្ស គឺពិតជានឹងទទួលរងនូវរាល់បញ្ហា មានទុក្ខវិបត្តិ ចលាចល បរិយាកាសអ័ព្ទអួ និងការប្រែប្រួលផ្លាស់ប្តូរនូវរូបធាតុទាំងឡាយ ។

At the same time, man’s mind can change this unfortunate situation of the world and can make peaceful, prosperous, and happy world for all to live in if man uses his mind properly. This can be done only through the purified mental energy.

ជាមួយគ្នានេះ ចិត្តរបស់បុគ្គលគ្រប់រូបក៏អាចផ្លាស់ប្តូរ ឬកែប្រែនូវស្ថានភាពនៃពិភពលោកដ៏អ័ព្ទអួនេះបាន ព្រមទាំងអាចញុំាងពិភពលោកនេះឱ្យជួបតែនឹងសុខសន្តិភាព ថ្កុំថ្កើងរុងរឿង សម្បូរសប្បាយសម្រាប់ជនទូទៅបានទៀតផង ប្រសិនបើមនុស្សទាំងឡាយនោះ ចេះប្រើប្រាស់ចិត្តរបស់គេឱ្យបានត្រឹមត្រូវ។ ប្រការទាំងនេះ អាចត្រូវធ្វើទៅបានមានតែតាមវិធីជម្រះចិត្តឱ្យស្អាតបរិសុទ្ធចាកគ្រឿងសៅហ្មងទាំងឡាយប៉ុណ្ណោះ ។

## FACE FACTS
## ប្រឈមនឹងការពិត

Buddhism is a religion which always encourages man to face facts of life without acting as a hypocrite and to accept the truth whatever and wherever it may be. Therefore, Buddhists do not reject the facts pertaining to worldly matters discovered by great thinkers and scientists. Although the Buddha had paid more attention to spiritual development, he never neglected man's worldly progress.

ពុទ្ធសាសនា ជាសាសនាដែលតែងតែលើកទឹកចិត្តមនុស្សឱ្យហ៊ានប្រឈមមុខនឹងបញ្ហាជីវិតដោយមិនរួញរា និងទទួលស្គាល់ការពិត មិនថាវាជាអ្វី ហើយនៅកន្លែងណាឡើយ ។ ដូចនេះពុទ្ធសាសនិកទាំងឡាយ មិនត្រូវបដិសេធចោលនូវព្រឹត្តិការណ៍ ដែលជាប់ពាក់ព័ន្ធនឹងលោកីយ៍ (ពិភពលោក) ដែលត្រូវបានស្រាវជ្រាវរាវរកឃើញដោយទស្សនវិទូ និងអ្នកវិទ្យាសាស្រ្តទាំងឡាយទេ ។ ទោះបីជា ព្រះសម្មាសម្ពុទ្ធបានសង្កត់ធ្ងន់លើការចម្រើនវិបស្សនា (ចម្រើនបញ្ញា) តែព្រះអង្គក៏មិនដែលបដិសេធចោលនូវវិស័យលោកីយ៍របស់មនុស្សលោកដែរ ។

In his teachings, we can find some sound and practical advices for man to work properly without wasting valuable time and effort and to act wisely for the progress of mankind. He said that man should fulfill his duties towards his family, relatives, friends, community, his country, and the whole world.

នៅក្នុងព្រះពុទ្ធដីកា យើងអាចឃើញមានដំបូន្មានដ៏ប្រពៃពិតៗ សម្រាប់មនុស្សលោកប្រតិបត្តិក្នុងការប្រកបការងារឱ្យបានប្រសើរ ដោយមិនឱ្យចំណាយពេលវេលាឥតប្រយោជន៍ តែត្រូវមានសេចក្តីព្យាយាម ព្រមទាំងត្រូវធ្វើការងារប្រកបដោយបញ្ញា (មនសិការ) ។ ព្រះអង្គបានទ្រង់សំដែងទៀតថា មនុស្សម្នាក់ៗគប្បីបំពេញភារកិច្ចរបស់ខ្លួនចំពោះគ្រួសារ សាច់ញាតិ មិត្រភក្តិ សហគមន៍ ប្រទេសជាតិរបស់ខ្លួន ព្រមទាំងពិភពលោកទាំងមូល ។

Therefore, Buddhists should not ignore their duties and obligations to make this a happy and peaceful world by contributing their share within their capacity. He also did not interfere with the affairs of government or with reasonable laws imposed by government. He was not against any social custom and tradition if they are harmless and useful to the society.

ដូចនេះពុទ្ធបរិស័ទទាំងឡាយមិនគួរគប្បីព្រងើយកន្តើយចំពោះភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនក្នុងការញុំាងពិភពលោកនេះឱ្យឈានទៅរកភាពសប្បាយរុងរឿង និងសុខសន្តិភាព ដោយការចេះចែករំលែកនូវសមត្ថភាពរបស់ខ្លួនដល់គ្នា នឹងគ្នាឡើយ ។ ព្រះពុទ្ធអង្គមិនបានជ្រៀតជ្រែក (ពាក់ព័ន្ធ) ជាមួយរដ្ឋាភិបាល ឬច្បាប់ដែលមានហេតុផលសមរម្យបានតាក់តែងឡើងដោយរដ្ឋាភិបាលឡើយ ។ ព្រះអង្គមិនបានប្រឆាំងជំទាស់ទៅនឹងទំនៀមទំលាប់ប្រពៃណីសង្គមណាមួយទេ ប្រសិនបើទំនៀមទំលាប់ប្រពៃណីទាំងនោះគ្មានគ្រោះថ្នាក់ និងមានប្រយោជន៍ដល់សង្គមនោះ ។

At the same time, he also never sought political or military power to introduce his way of religious life although the kings and the ministers were His followers.

ទន្ទឹមគ្នានេះ ព្រះដ៏មានបុណ្យមិនដែលស្វែងរកអំណាចនយោបាយ ឬអំណាចយោធាដើម្បីដាក់បញ្ចូលក្នុងមាគ៌ាជីវិតសាសនារបស់ព្រះអង្គទេ ទោះបីព្រះមហាក្សត្រ និងរដ្ឋមន្ត្រីទាំងឡាយក៏ជាសាវ័ករបស់ព្រះអង្គដែរ ។

This is a religion, which teaches us to serve others, to sacrifice our own comfort for the sake precepts or disciplines voluntarily but not as commandments imposed by some unseen beings. By own conviction not only that we get the chance to be perfect but we also help others to live in peace.

នេះគឺជាសាសនាដែលបង្រៀនយើងទាំងអស់គ្នាឱ្យចេះជួយសង្គ្រោះអ្នកដទៃ ចេះលះបង់នូវសេចក្តីសុខផ្ទាល់ខ្លួន សម្រាប់ជាប្រយោជន៏ដល់កិរិយារលាស់ចោលនូវសេចក្តីទុក្ខ និងព្យាយាមរក្សាសីល ឬអប់រំខ្លួនឱ្យមានវិន័យ តាមការស្ម័គ្រចិត្ត មិនមែនដោយការបង្គាប់បញ្ជា ដូចដែលបានដាក់កំហិតដោយពួកអមនុស្សនោះឡើយ ។ ការរក្សាសីលនេះគឺយោងតាមជំនឿរបស់ខ្លួនផ្ទាល់ មិនមែនគ្រាន់តែថា យើងទទួលបាននូវសេចក្តីសុខតែម្នាក់ឯងប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវជួយអ្នកដទៃឱ្យរស់នៅ ប្រកបដោយសុខសន្តិភាពផងដែរ ។

This perfection is the highest goal, which a person must attain in order to gain his salvation. It cannot be obtained through the influence of any God.

ការបំពេញសីលនេះ គឺជាគោលដៅដ៏ខ្ពង់ខ្ពស់បំផុតដែលមនុស្សម្នាក់ៗត្រូវទទួលបាន ដើម្បីឱ្យបានសម្រេចដល់ទីបំផុតនៃទុក្ខ ។ គេមិនអាចទទួលបាននូវគោលដៅដ៏ឧត្តមនេះ តាមរយៈឥទ្ធិពលនៃព្រះអាទិទេពណាមួយឡើយ ។

## COME AND SEE THE RESULTS IMMEDIATELY

## ឃើញផលភ្លាមៗ

According to this religion we can see the results of most of our good and bad actions within this life time. Heavenly bliss or Nirvanic bliss can be experienced within this life time. It is not necessary to wait to see the results only after our death as taught by many other religions.

តាមរយៈពុទ្ធសាសនា យើងអាចឃើញផលនៃអំពើរបស់យើងទាំងល្អក្តី ទាំងអាក្រក់ក្តី នៅក្នុងជាតិនេះ ។ ហើយសុខឋានសួគ៌ ឬសុខព្រះនិព្វានក៏អាចត្រូវបានទទួលក្នុងជាតិនេះផងដែរ ដោយមិនចាំបាច់រង់ចាំទទួលផលបន្ទាប់ពីការស្លាប់ទៅរបស់យើង ដូចត្រូវបានបង្រៀនដោយពាហិរសាសនានោះទេ ។

That is why the Buddha always welcomes people to come and see his way of teachings but not to come and believe it at once. He also advised people on how to choose a proper religion by considering and investigating in various ways without accepting anything through emotion or blind faith.

នោះជាមូលហេតុ ដែលព្រះសម្មាសម្ពុទ្ធតែងតែប្រៀនប្រដៅមនុស្សលោកទាំងឡាយ ឱ្យសិក្សាឈ្វេងយល់ពីពាក្យប្រៀនប្រដៅរបស់ព្រះអង្គ តែមិនមែនឱ្យមកជឿភ្លាមៗឡើយ ។ ព្រះអង្គថែមទាំងបានទូន្មានមនុស្សទាំងឡាយទាំងពួងពីរបៀបជ្រើសរើសយកសាសនាឱ្យបានប្រពៃ ឆ្លងកាត់ការពិចារណាថ្លឹងថ្លែង និងស៊ើបអង្កេតបានត្រឹមត្រូវ មិនមែនចេះតែកាន់តាម ឬជឿតាមដោយក្តីងងឹតងងុល (ជំនឿផ្តាប់មុខ) នោះទេ ។

This is why Buddhism is called a doctrine of analysis. Here in this religion, we can see the scientific and psychological analysis of mind and matter which modern great thinkers can appreciate.

នេះក៏ជាមូលហេតុដែលពុទ្ធសាសនាត្រូវបានគេហៅថា "សាសនាវិភាគទស្សនៈ" ។ ក្នុងសាសនានេះយើងអាចជួប ឬឃើញនូវការវិភាគវែកញែក នៃ**នាម** និង**រូប** តាមបែបវិទ្យាសាស្ត្រ និងចិត្តសាស្ត្រដ៏អស្ចារ្យ ដែលទស្សនវិទូសម័យថ្មីអាចស្ញប់ស្ញែងថ្លែងនូវការសរសើរ ។

## UNIVERSAL LAWS

## ច្បាប់សាកល

To those who talk about the first cause of this world, the Buddha has said that it is impossible to find a first cause since everything is changing, interdependent and conditioned by others. The things that acted once as cause next may become the effect and after sometime that effect may become the cause again. This phenomenon will continue without stopping. This phenomenon is called universal law of Anicca or impermanency.

ចំពោះបុគ្គលដែលនិយាយពីហេតុដែលកកើតពិភពលោកនេះដំបូង ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា វាហួសវិស័យនឹងគិត ឬស្វែងរកនូវហេតុដំបូង ព្រោះថាអ្វីៗមានការប្រែប្រួលពឹងពាក់អាស្រ័យគ្នា ហើយនឹងមានបច្ច័យ ឬល័ក្ខខ័ណ្ឌរបស់ខ្លួនផ្សេងៗទៀត ។ វត្ថុដែលដើរតួជាហេតុនៅពេលមួយ វាអាចដើរតួជាផលនៅពេលក្រោយ ហើយបន្ទាប់ពីផលនោះ វាក៏អាចវិលមកជាហេតុវិញ។ សភាវៈនេះនឹងធ្វើដំណើររហូត ដោយគ្មានឈប់ឈរឡើយ ។ សភាវៈទាំងនេះ ហើយដែលត្រូវបានគេហៅថា ច្បាប់អនិច្ចំ ពោលគឺសេចក្ដីមិនទៀងទាត់នោះ ។

The Buddha was the teacher who discovered the real nature of the universal cosmic law and who advised people to live in accordance with this law. He mentioned that those who violate this law, such as going against nature and lead an immoral life, must be ready to face the consequences.

ព្រះសម្មាសម្ពុទ្ធ គឺជាគ្រូដែលបានស្រាវជ្រាវរាវរកឃើញនូវធម្មជាតិ ពិតនៃច្បាប់សាកល ហើយក៏ជាអ្នកប្រៀនប្រដៅសត្វលោកឱ្យរស់នៅសមស្របតាមច្បាប់នេះ ។ ព្រះអង្គទ្រង់ពន្យល់ថា សត្វលោកណាបំពាន (ប្រព្រឹត្តល្មើស) ទៅនឹងច្បាប់នេះ បីដូចជាប្រឆាំងនឹងធម្មជាតិ ហើយនឹងរស់នៅចិញ្ចឹមជីវិតប្រកបដោយអសីលធម៌ ច្បាស់ជាត្រូវត្រៀមខ្លួនប្រឈមមុខនឹងបញ្ហាជាក់ជាមិនខានឡើយ ។

It is impossible to escape from the reactions of such this universal law is unbiased. It is impossible to escape from the reaction of this law. But the Buddha has taught us how to stop the reactions of deeds, by training the mind and eradicating evil thoughts from the mind. After violating the cosmic order there is no other method to get rid of the reaction except by co-operating with the same cosmic law.

វាមិនអាចគេចផុតពីក្រញាំនៃច្បាប់សាកលនេះងាយៗ ដោយគ្រាន់តែអធិដ្ឋានដល់ព្រះអាទិទេពបានទេ ព្រោះច្បាប់នេះមិនមានភាពលំអៀង ឬមិនមានអគតិ។ អ្វីៗពិតជាមិនអាចគេចចេញពីច្បាប់នេះបានឡើយ វៀរលែងតែព្រះនិព្វានមួយចេញ។ ប៉ុន្តែព្រះសម្មាសម្ពុទ្ធបានសំដែងប្រាប់យើងទាំងអស់គ្នា នូវមធ្យោបាយឱ្យឈប់ប្រព្រឹត្តអំពើអាក្រក់ ដោយការព្យាយាមធ្វើតែអំពើល្អ ហ្វឹកហាត់អប់រំផ្លូវចិត្ត និងជម្រះចិត្តឱ្យស្អាតចាកគ្រឿងសៅហ្មងទាំងឡាយ ។ ក្រៅពីការសម្របសម្រួលនឹងច្បាប់នេះសាជាថ្មី បន្ទាប់ពីប្រព្រឹត្តល្មើសនឹងច្បាប់សាកលនោះ ក៏គ្មានវិធីសាស្ត្រណាអាចត្រូវបានគេយកមកប្រើដើម្បីលុបបំបាត់នូវកម្មវិបាកនោះបានទេ។

## MENTAL CURRENT

## ចរន្តចិត្ត

The Karma that the Buddha has explained is accepted by the world famous psychologist Carl Jung as collective consciousness. This is nothing but the depositary of karma seeds in mental energy.

ទ្រឹស្តីកម្មផលដែលព្រះសម្មាសម្ពុទ្ធបានសំដែងមក ត្រូវបានទទួលស្គាល់ដោយលោក ***ខាល ជុង*** (Carl Jung) ជាអ្នកចិត្តសាស្ត្រពិភពលោកដ៏ល្បីថា ជាបណ្តុំនៃចិត្ត ឬចេតនា ។ ចិត្ត ឬចេតនា គឺគ្មានអ្វីក្រៅពីកំលាំងកម្មដែលបានសាបព្រោះទុកក្នុងចិត្តឡើយ ។

As long as the collective consciousness and "will to live" remain in the mind as mentioned by the philosophers also, rebirth will take place whether people believe it or not. The elements of the body may disintegrate but mental current together with "will to live" will be transmitted and another life will be conditioned according to that collective consciousness.

ដរាបណានៅតែមានចេតនា និងឆន្ទៈចង់រស់ ដូចបានអធិប្បាយ ដោយទស្សនវិទូទាំងឡាយ ការកកើតក៏នៅតែមានដរាបនោះ បើទោះបីជាថា មនុស្សជឿ ឬមិនជឿក៏ដោយ ។ រូបធាតុអាចបែកធ្លាយចេញពីគ្នា ប៉ុន្តែចេតនា និងឆន្ទៈចង់រស់នឹងត្រូវបានផ្ទេរបញ្ជូនទៅដោយកំលាំងកម្ម ហើយជីវិតមួយផ្សេងទៀតក៏ត្រូវបានតាក់តែងឡើងអាស្រ័យលើកម្មនេះឯង ។

Gravitation and law of conservation of energy discovered by the modern scientists like Newton support the doctrine of karma of action and reaction introduced by the Buddha.

ទំនាញផែនដី និងច្បាប់រក្សាទំនាញផែនដីត្រូវបានរកឃើញ ដោយអ្នកវិទ្យាសាស្ត្រម្នាក់ឈ្មោះលោក ***ញូ តុន*** (Newton) ក៏បានគាំទ្រនូវទ្រឹស្តីកម្មផលដែលបានសំដែងដោយព្រះសម្មាសម្ពុទ្ធផងដែរ ។

## MAN CAN BECOME GOD

## មនុស្សអាចក្លាយជាព្រះអាទិទេព

According to the Buddha man can even become a god if he leads a decent and righteous way of life irrespective of his religious beliefs, but other religions only advise man to pray to god to get blessings.

យោងតាមព្រះសម្មាសម្ពុទ្ធ សូម្បីតែមនុស្សសាមញ្ញក៏អាចក្លាយជាព្រះអាទិទេពបានដែរ ប្រសិនបើមនុស្សនោះដឹកនាំមាគ៌ាជីវិតស្របតាមគន្លងធម៌ ដោយមិនគិតដល់ជំនឿសាសនារបស់គេ ប៉ុន្តែសាសនាផ្សេងៗទៀត ទូន្មានមនុស្សបានត្រឹមតែឱ្យសំបូងសង្រួងបួងសួងអធិដ្ឋានដល់ព្រះអាទិទេព សូមសេចក្តីសុខប៉ុណ្ណោះ ។

They also preach that only after death can man go to heaven, but that heavenly bliss or experience does not mean that man too can get the privilege to become a god. However, Buddhist concept of god is different from that of other religions.

ពួកគេប្រៀនប្រដៅថា បន្ទាប់ពីស្លាប់ភ្លាមមនុស្សអាចទៅកើតនៅស្ថានសួគ៌ ប៉ុន្តែការសូមពរ ឬការបួងសួងមិនមែនមានន័យថា មនុស្សអាចទទួលឯកសិទ្ធិក្លាយជាព្រះអាទិទេពនោះទេ ។ ទោះបីជាយ៉ាងណា ទ្រឹស្តីអាទិទេពរបស់ពុទ្ធសាសនា គឺផ្សេងពីទស្សនៈអាទិទេពរបស់ពាហិរសាសនា ។

No founder of a religion has ever said that the followers too can one day get the chance to gain the same experience, the same peace, happiness and the same salvation as did the founder

of that religion. But the Buddha has said that anyone can become a Buddha if one can practise the same perfection, the same method practised by Him.

មិនមានមេសាសនាណាមួយធ្លាប់បាននិយាយថា ថ្ងៃណាមួយបរិស័ទទាំងឡាយរបស់គេអាចមានឱកាសសម្រេចបាននូវបទពិសោធន៍ សន្តិភាព សេចក្តីសុខ ហើយនឹងផុតទុក្ខដូចគ្នា ដូចដែលមេសាសនានោះបានធ្វើក៏ទេដែរ។ ប៉ុន្តែព្រះសម្មាសម្ពុទ្ធបានត្រាស់សំដែងថា នរណាមួយក៏អាចក្លាយជាព្រះពុទ្ធបាន ឱ្យតែបុគ្គលនោះអាចបំពេញនូវបារមី វិធីប្រតិបត្តិ ដូចដែលព្រះអង្គបានអនុវត្ត ។

## THE NATURE OF THE MIND
## សភាពនៃចិត្ត

The rapid changes of mind and the elements of the body have been explained in Buddhism. According to the Buddha, in every fraction of a split second the mind appears and disappears. Biology, physiology and psychology also teach the same nature of change in life. Therefore life is not static.

ការប្រែប្រួលដ៏រហ័សនៃនាម និងរូបត្រូវបានពន្យល់នៅក្នុងព្រះពុទ្ធសាសនា ។ តាមពុទ្ធដីកា គ្រប់ចម្រៀកនៃវិនាទី ចិត្តបានកើតឡើង និងរលត់ទៅវិញ។ ជីវវិទ្យាក្តី រូបវិទ្យាក្តី និងចិត្តវិទ្យាក្តី ក៏បានបង្រៀនពីការប្រែប្រួលផ្លាស់ប្តូរនៃធម្មជាតិដូចគ្នាដែរ ក្នុងជីវិតរស់នៅ ។ ដូច្នេះ ជីវិតគ្មានស្ថិរភាពឡើយ ។

Another psychologist, Prof. William James has explained about the point-moment of consciousness. He pointed out how consciousness comes into being and passes away again in rapid succession.

អ្នកចិត្តសាស្ត្រមួយទៀត ឈ្មោះលោកសាស្ត្រាចារ្យ ***វិលល្យែម ជេម*** (William James) បានពន្យល់អំពីខណៈនៃចិត្ត។ គាត់បានពន្យល់ថា របៀបចិត្តកើតឡើងក្នុងសព្វសត្វ ហើយរលត់ទៅវិញក្នុងដំណើរតៗគ្នាយ៉ាងរហ័ស។

According to the nature that causes the continuous process of mind, as soon as a thought is born, it gives birth to another thought and dies. The thought that is born in turn gives birth to another thought and dies and so on.

ផ្អែកតាមធម្មជាតិ ដែលបណ្តាលឱ្យមានដំណើរការជាបន្តបន្ទាប់នៃចិត្ត "នៅខណៈពេលគំនិតនោះកើត វាក៏ផ្តល់កំណើតឱ្យចិត្តមួយទៀត ហើយស្លាប់ទៅ ។ ចិត្តដែលកើតឡើងប្តូរវេនគ្នាឱ្យទៅចិត្តមួយទៀត និងរលត់ទៅវិញ ហើយកើតផ្សេងៗទៀត ជាបន្តបន្ទាប់" ។

To the question, how evil thoughts appeared in man’s mind at the beginning, the answer can be found in this religion. The cause of those evil thoughts is man’s selfish motives which exist due to craving for existence.

ត្រង់សំនួរថា "តើអកុសលចិត្តកើតក្នុងចិត្តរបស់មនុស្សយ៉ាងដូចម្តេចនៅពេលដំបូង?" ចម្លើយអាចត្រូវបានគេស្វែងរកឃើញនៅក្នុងព្រះពុទ្ធសាសនា។ ឫសគល់នៃអកុសលចិត្តទាំងឡាយ គឺស្ថិតនៅក្នុងទង្វើអាត្មានិយមរបស់មនុស្សដែលតាំងមាននៅដោយសារកាមភពនោះឯង។

## EVERYTHING IS OPEN

## អ្វីៗគ្រប់យ៉ាងគឺបើកទូលំទូលាយ

When we study the life and the teachings of the Buddha we can see that everything is open to everybody. There are no secret doctrines. The events which took place during his whole life were open and there were no hidden and mystical incidents.

ពេលយើងសិក្សាឈ្វេងយល់ពីជីវិត និងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ យើងយល់ថា "អ្វីៗគឺទូលំទូលាយណាស់សម្រាប់មនុស្សលោក" ។ គ្មានធម៌ទាំងឡាយណាជាអាថ៌កំបាំងទេ ។ ព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងកំឡុងពេលរស់នៅរបស់មនុស្ស គឺពិតជាបើកចំហដោយសេរី ហើយគ្មានអ្វីលាក់បាំង និងគ្មានឧប្បត្តិហេតុជាអាថ៌កំបាំងឡើយ ។

In the eyes of the Buddha, so called supernatural powers to many people are not supernatural but only natural phenomena which ordinary man cannot understand.

ក្នុងចក្ខុវិស័យរបស់ព្រះសម្មាសម្ពុទ្ធ អ្វីដែលយើងហៅថាវត្ថុអមតៈ ចំពោះមនុស្សទាំងឡាយនោះ មិនមែនជាអព្ភូតហេតុអស្ចារ្យទេ ប៉ុន្តែគ្រាន់តែជាបាតុភូតធម្មជាតិដែលមនុស្សធម្មតាយល់មិនដល់ប៉ុណ្ណោះ ។

If the component things are subject to the natural laws of change – decay and death, how can we introduce them as supernatural powers?

ប្រសិនបើសង្ខារធម៌ទាំងឡាយស្ថិតក្នុងច្បាប់អនិច្ចំ : ឈឺ និងស្លាប់ទាំងអស់ តើយើងអាចពន្យល់ណែនាំថា វាជាវត្ថុអមតៈដូចម្ដេច? ។

Even the Buddha's birth, enlightenment and death had also taken place in normal circumstances. He lived as a normal religious teacher.

សូម្បីតែការប្រសូត្រ ការត្រាស់ដឹង និងការចូលព្រះបរិនិព្វានរបស់ព្រះអង្គក៏ប្រព្រឹត្តទៅតាមកាលៈទេសៈសាមញ្ញធម្មតាដែរ ។ កាលព្រះអង្គទ្រង់ធរមាននៅ ក៏ដូចជាគ្រូសាសនាសាមញ្ញទាំងឡាយទាំងពួង ។

## PROCESS OF EVOLVING

## ដំណើរនៃការវិវត្ត

The Buddha has pointed out the process of evolving from the animal life into human status and from human status into divine status. Divine life into Brahma status and Brahma life into perfect life.

ព្រះសម្មាសម្ពុទ្ធបានសំដែងទុកមក នូវដំណើរវិវត្តពីជីវិតជាសត្វតិរច្ឆានទៅជាមនុស្ស និងពីឋានមនុស្សទៅឋានទេវតា ។ ពីជីវិតជាទេវតាទៅជីវិតជាព្រហ្ម និងពីជីវិតជាព្រហ្មទៅជីវិតឥតខ្ចោះ គឺព្រះនិព្វាន ។

One can also proceed from noble pure life directly into perfect holy life. The Buddha has pointed out the reverse order as well, that is, going from human life into animal life.

បុគ្គលណាមួយ ក៏អាចធ្វើដំណើរពីជីវិតដ៏ថ្លៃថ្លាបរិសុទ្ធដោយផ្ទាល់ទៅកាន់ជីវិតឥតខ្ចោះបានផងដែរ ។ ព្រះសម្មាសម្ពុទ្ធក៏ទ្រង់បានសំដែងអំពីដំណើរបញ្ច្រាសត្រឡប់ផងដែរ ពោលគឺការវិលពីមនុស្សជាតិទៅកើតជាកំណើតសត្វតិរច្ឆានវិញ ។

## MODERATE WAY OF LIFE

## អរិយមគ្គ

The Buddha has advised people to follow the middle path in every aspect of their life. But many people have not realised the real meaning and usefulness of this noble middle path.

ព្រះសម្មាសម្ពុទ្ធបានទូន្មានមនុស្សឱ្យប្រតិបត្តិ តាមមាគ៌ាកណ្តាលគ្រប់ទិដ្ឋភាពនៃជីវិត ។ ប៉ុន្តែមនុស្សភាគច្រើនមិនបានដឹងនូវអត្ថន័យពិត និងប្រយោជន៍ពិតនៃមជ្ឈិមប្បដិបទានេះឡើយ ។

The deep meaning of this middle path is not only a righteous way of life, not only avoiding two extremes of life, and not only leading a moderate life but to learn how to use our human senses or faculties without misusing or abusing them. The meaning of the formation of these senses is to protect our life, to avoid certain dangers and to find out our livelihood.

អត្ថន័យដ៏ជ្រាលជ្រៅនៃមជ្ឈិមប្បដិបទានេះ គឺមិនមែនគ្រាន់តែជាមាគ៌ាជីវិតដ៏ប្រពៃ មិនមែនគ្រាន់តែដើម្បីវៀរចាកអន្តធម៌ពីរប្រការប៉ុណ្ណោះទេ ហើយក៏មិនមែនគ្រាន់តែដឹកនាំជីវិតឱ្យស្គាល់ប្រមាណឡើយ ប៉ុន្តែថែមទាំងដើម្បីឱ្យដឹងពីរបៀបប្រើប្រាស់វិញ្ញាណ ឬឥន្ទ្រីយ៍របស់យើងឱ្យបានត្រឹមត្រូវដោយគ្មានការបំពារបំពានគេផងដែរ ។ អត្ថន័យនៃសង្ខារវិញ្ញាណនេះ គឺដើម្បីការពារជីវិតរបស់យើង ជួយបញ្ចៀសយើងឱ្យផុតពីអន្តរាយ និងយល់ពីការរស់នៅ ។

But unfortunately, many people spend their whole life only for the gratification of these senses and misuse them to satisfy only their desires. Finally, their craving becomes more intense but they never get the satisfaction they crave for.

ប៉ុន្តែគួរឱ្យសោកស្តាយណាស់ មនុស្សមួយចំនួនបានចំណាយពេលពេញមួយជីវិតរបស់គេ សម្រាប់បំពេញនូវអារម្មណ៍តាមឥន្ទ្រីយ៍ទាំងនេះ ហើយប្រើវាខុសទិសដៅ ដើម្បីបំពេញចំណីចំណង់តណ្ហា ។ ទីបំផុតតណ្ហារបស់ពួកគេកាន់តែធំធាត់ឡើងៗ ប៉ុន្តែគេមិនដែលទទួលស្គាល់ការពេញចិត្តថា ពួកគេមានចំណង់ទេ ។

Many immoral practices, cruel deeds, mental disturbances, nervous breakdowns, unhealthy competition, tension and unrest which are very common in the modern misused the senses.

ការប្រព្រឹត្តអំពើអសីលធម៌ អំពើឃោរឃៅ ចលាចលផ្លូវចិត្ត ការបរាជ័យដ៏ធ្ងន់ធ្ងរ ការខូចសុខភាព ភាពតានតឹង និងការរវើរវាយបានក្លាយជាបញ្ហាដ៏សាមញ្ញបំផុត នៅក្នុងសង្គមទំនើបយើងបច្ចុប្បន្ន ។ នេះគឺដោយសារតែចិត្តទោមនស្សដែលដើរខុសគន្លងនោះឯង ។

Then the instinctive power of these senses also gradually starts to decay and many types of sickness appear in the human organs. That is how man pays the price for misusing or overtaxing his own five senses. If there is too much attachment to sensual pleasure in this world, we have no time to mould and prepare for our future life or the next world, and then it will become a miserable one.

បន្ទាប់មកទៀត ឥទ្ធិពលចិត្តដែលកើតពីសភាវគតិចាប់ចុះខ្សោយបន្តិចម្តងៗ ជំងឺគ្រប់ប្រភេទក៏កើតមានក្នុងរូបរាងកាយមនុស្ស ។ នោះគឺជារបៀបដែលមនុស្សទាំងឡាយ ចំណាយពេលវេលាដ៏មានតំលៃក្នុងផ្លូវខុស ឬផ្គាប់ផ្គុនឥន្ទ្រីយ៍ទាំងប្រាំហួសហេតុពេក ។ បើសិនមានចំណង់តណ្ហាខ្លាំងក្លានៅក្នុងលោកនេះ យើងពិតជាគ្មានពេលអប់រំបន្ទំ-និស្ស័យ និងប្រុងប្រៀបរៀបចំខ្លួនសម្រាប់ថ្ងៃអនាគត ឬលោកខាងមុខឡើយ ។ អញ្ចឹង វាពិតជាក្លាយទៅជាបញ្ហាទុក្ខលំបាកមួយ ។

## BUDDHIST ATTITUDE
## ឥរិយាបថព្រះពុទ្ធសាសនា

The Buddha has advised that it is cruel and unfair for us to destroy any living beings, but many other religious teachers have ignored this aspect. Destroying the lives of other living beings is not the only solution to get rid of the nuisance created by them.

ព្រះសម្មាសម្ពុទ្ធបានប្រៀនប្រដៅថា វាឃោរឃៅសាហាវយង់ឃ្នង និងអយុត្តិធម៌ណាស់សម្រាប់យើងទាំងអស់គ្នា ដែលនាំគ្នាបំផ្លិចបំផ្លាញជីវិតសត្វទាំងឡាយ ប៉ុន្តែមេពាហិរសាសនាភាគច្រើនបានបដិសេធចោលនូវទស្សនៈនេះ ។ ការបៀតបៀនបំផ្លិចបំផ្លាញជីវិតសត្វដទៃ គឺមិនមែនជាដំណោះស្រាយដើម្បីរំដោះចេញពីសេចក្តីសៅហ្មងចិត្ត ឬសេចក្តីទុក្ខ ដូចដែលត្រូវបានបង្កើតឡើងដោយពួកមេសាសនាទាំងនោះទេ ។

The aim of Buddhism is to awaken mankind to the attainment of the highest happiness through clear understanding of life and nature. Its aim is not to create certain wild imagination in the mind or to please the emotion of the people or to indulge in uncertain worldly desires. It also does not promise eternal mundane pleasure anywhere.

ទិសដៅពុទ្ធសាសនា គឺដើម្បីដាស់តឿនក្រើនរំលឹកមនុស្សលោកឱ្យបានសម្រេចនូវអតិបរមសុខ សុភមង្គលដោយសារការយល់ដឹងពីជីវិត និងធម្មជាតិពិត១ ។ គោលការណ៍ពុទ្ធសាសនាមិនមែនបង្កើតឡើង ឱ្យមានការរវើរវាយ ភាពស្មុគស្មាញក្នុងចិត្ត មិនមែនធ្វើឱ្យអារម្មណ៍របស់មនុស្សភ្លើតភ្លើន ឬក៏ផ្តេកផ្តួលទៅតាមសេចក្តីសុខលោកិយ៍ក្លែងក្លាយក៏ទេដែរ។ ពុទ្ធសាសនាមិនដែលសន្យាថា សេចក្តីសុខលោកិយ៍នេះថា ជាសុខអមតៈត្រង់ណាមួយសោះឡើយ ។

## REAL NATURE OF LIFE
## ធម្មជាតិពិតនៃជីវិត

Buddhism gives a clear picture of both sides of life. The real nature of life – the cause of suffering and the cause of happiness. Medical theory, science and technology have not discovered any remedy for man’s mental pain; frustration and unsatisfactoriness of life.

ព្រះពុទ្ធសាសនា ផ្តល់នូវរូបភាពនៃជីវិតទាំងពីរផ្នែកយ៉ាងច្បាស់ ។ ធម្មជាតិពិតនៃជីវិត ពោលគឺបានដល់ហេតុនាំឱ្យកើតទុក្ខ និងហេតុនាំឱ្យកើតសេចក្តីសុខ។ ទ្រឹស្តីវេជ្ជសាស្ត្រ (គីមី) វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា មិនទាន់ស្រាវជ្រាវរាវរកឃើញនូវឱសថណាមួយសម្រាប់ព្យាបាលជំងឺផ្លូវចិត្ត ជំងឺខូចចិត្ត និងសេចក្តីទុក្ខទេ។

The purpose of life is a very complicated issue since different people give different interpretations. However, from the Buddhist point of view it is only to find out a complete solution for the problems of life and the attainment of unconditioned state of happiness.

គោលបំណងនៃជីវិតគឺជាបញ្ហាដ៏ស្មុគស្មាញមួយ ព្រោះមនុស្សទាំងឡាយ បានផ្តល់នូវបំណកស្រាយផ្សេង១គ្នា ។ ទោះបីជាយ៉ាងណាក៏ដោយ តាមទស្សនៈពុទ្ធសាសនា គឺវាគ្រាន់តែជាការស្វែងរកនូវដំណោះស្រាយពេញលេញមួយសម្រាប់បញ្ហាជីវិត ហើយនឹងការទទួលបាននូវឯកន្តបរមសុខ។

## WHAT IS WISDOM?
## តើអ្វីជាបញ្ញា?

From the Buddhist point of view, wisdom is based on right understanding and right thought, the realisation of the universal law and development of insight not only to see the truth but also to perceive the way for complete liberation of unsatisfactoriness of life.

តាមទស្សនៈពុទ្ធសាសនា បញ្ញាត្រូវបានពោលសំដៅទៅលើសម្មាទិដ្ឋិ (ការយល់ត្រូវ) និងសម្មាសង្កប្បៈ (ការត្រិះរិះត្រូវ) ការយល់ដឹងជាក់លាក់ពីច្បាប់សាកល និងការចម្រើននូវវិបស្សនា មិនត្រឹមតែឃើញនូវសច្ចភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំឱ្យដល់ទីបំផុតទុក្ខ ពោលគឺព្រះនិព្វានទៀតផង ។

Therefore, real wisdom cannot be found in academic institutions or in the laboratory of scientific research or in a place of worship where people always go and pray or perform certain rites and rituals. The wisdom is within the mind.

ម្ល៉ោះហើយ បញ្ញាពិតមិនអាចត្រូវបានគេស្រាវជ្រាវរកឃើញនៅក្នុងស្ថាប័នអប់រំនៅមហាវិទ្យាល័យ ឬនៅក្នុងទីពិសោធន៍នៃវិទ្យាសាស្ត្រ ឬថានៅកន្លែងបូជាដែលមនុស្សទាំងឡាយតែងតែទៅបន់ស្រន់បួងសួង ឬក៏ធ្វើវិធីប្រតិបត្តិមួយចំនួន ។ បញ្ញាគឺស្ថិតនៅក្នុងចិត្ត ។

When the experience, understanding, realisation and purification are completed, this wisdom, comprising of the highest perfection can be seen. The aim of life is the attainment of this wisdom. Instead of searching what there is in outer space, if man makes the effort to find out the nature of inner space, man can reach his final goal.

នៅពេលការពិសោធ ការឈ្វេងយល់ ការចាក់ធ្លុះ និងការជម្រះចិត្តឱ្យស្អាតបរិសុទ្ធបានពេញលេញហើយ បញ្ញាដ៏ឧត្តមនេះអាចត្រូវបានមើលឃើញដោយពិត ។ គោលដៅនៃជីវិតគឺការសម្រេចបាននូវបញ្ញានេះឯង ។ ជំនួសឱ្យការស្រាវជ្រាវរាវរក នូវអ្វីដែលមាននៅក្នុងលំហអាកាសខាងក្រៅ ប្រសិនបើមនុស្សព្យាយាមស្រាវជ្រាវ ឈ្វេងយល់នូវធម្មជាតិនៃលំហខាងក្នុងវិញ មនុស្សអាចទៅដល់គោលដៅរបស់គេបាន ។

Man can get rid of the worldly natural forces which are not favourable for him by strengthening and purification of his mind to attain supramundane state of happiness where these forces have no power to function anymore.

មនុស្សអាចកម្ចាត់ចោល នូវឥទ្ធិពលលោកីយ៍ដែលមិនជាទីពេញចិត្តរបស់គេ ដោយការពង្រឹង និងជម្រះចិត្តរបស់គេដើម្បីសម្រេចបាននូវលោកុត្តរសុខ ដែលឥទ្ធិពលទាំងនេះគ្មានថាមពលណាធ្វើជាមុខងារ ឬកិច្ចតទៅទៀតទេ ។

## A PRACTICAL METHOD
## វិធីបដិបត្តិ

One philosopher has said that religion contradicts all that man has ever experienced. If it is so Buddhism does not belong to that type of religion, since the Buddha has taught us everything through his experience.

ទស្សនវិទូម្នាក់បាននិយាយថា "សាសនានិយាយផ្ទុយពីអ្វីដែលមនុស្សបានធ្លាប់ជួបប្រទះទាំងអស់ " ។ ប្រសិនបើវាអញ្ចឹងមែន ពុទ្ធសាសនាមិនស្ថិតក្នុងប្រភេទសាសនាទាំងអស់នោះទេ ព្រោះព្រះសម្មាសម្ពុទ្ធបានប្រៀនប្រដៅយើងនូវអ្វីតាមបទពិសោធន៍ផ្ទាល់របស់ព្រះអង្គ ។

Many philosophers, great thinkers and scientists have used only their worldly knowledge, thinking power and wisdom to find out many things and they have expressed their views accordingly. Even with such intellectual knowledge it is impossible to understand the real nature of the phenomena without the purification of mind.

ទស្សនវិទូ អ្នកត្រិះរិះ និងអ្នកវិទ្យាសាស្ត្រទាំងឡាយ បានប្រើត្រឹមតែលោកិយវិជ្ជា ឥទ្ធិពលនៃគំនិត និងបញ្ញា ក្នុងការរុករកស្រាវជ្រាវនូវវត្ថុទាំងឡាយ ហើយពួកគេបានបង្ហាញនូវទស្សនៈរបស់គេតាមរយៈវត្ថុទាំងនោះ។ សូម្បីតែចំណេះនៃបញ្ញវន្តបែបហ្នឹង ក៏វាមិនអាចទៅរួចក្នុងការយល់ពីធម្មជាតិពិតនៃជីវិត ដោយគ្មានការជម្រះចិត្តឱ្យស្អាតបរិសុទ្ធ ឬភាពបរិសុទ្ធនៃចិត្តបានដែរ ។

When we  study certain statement made by some scholars we can see some truths in their sayings. But many of those sayings remain as dry philosophy because they have used only their brains with much illusion and egoism. But the Buddha has used his brain and heart both as refined human intelligence with compassion and wisdom to understand the things in their proper perspective. That is why his teaching has never become a dry philosophy or theory, but a practical method to solve human problems.

នៅពេលយើងសិក្សាពីឯកសារដែលនិពន្ធដោយអ្នកប្រាជ្ញមួយចំនួន យើងអាចឃើញមានភាពត្រឹមត្រូវខ្លះនៅក្នុងទស្សនៈរបស់គេ។ ប៉ុន្តែ ពាក្យពេចន៍ទាំងឡាយនោះ នៅតែជាទស្សនៈសោះកក្រោះ ព្រោះពួកគេបានប្រើគំនិតរបស់គេ មួយអន្លើដោយភាពអវិជ្ជា និងអត្តទត្ថភាព។ តែព្រះសម្មាសម្ពុទ្ធបានប្រើទស្សនៈ និងចិត្តរបស់ព្រះអង្គទាំងពីរជាបញ្ញាដ៏បរិសុទ្ធ ព្រមដោយសេចក្តីករុណា និងបញ្ញា ក្នុងការសិក្សាឈ្វេងយល់នូវវត្ថុទាំងឡាយ តាមលក្ខណៈផ្ទាល់របស់ខ្លួន ។ នោះជាមូលហេតុ ដែលពាក្យប្រៀនប្រដៅរបស់ព្រះអង្គ មិនជាទស្សនៈក្រៀមក្រោះ តែជាវិធីអនុវត្តក្នុងការដោះស្រាយបញ្ហាមនុស្សទាំងឡាយគ្រប់ជំពូក ។

## DOES REAL RELIGION HINDER WORLD PROGRESS?

## តើសាសនាពិត រារាំងការលូតលាស់នៃពិភពលោកឬ?

Many scientists, great thinkers and philosophers have adopted a hostile attitude towards religions. They say religions hinder the progress of mankind and mislead them by introducing ridiculous, superstitious beliefs and practices and try to keep people away from the facts discovered by the scientists. But when we  ascertain the way how they explain the meaning of religion, we can understand that Buddhism does not belong to those religious groups.

អ្នកវិទ្យាសាស្ត្រ អ្នកត្រិះរិះ និងទស្សនវិទូទាំងឡាយ បានប្រកាន់យកអាកប្បកិរិយាជាសត្រូវចំពោះសាសនាទាំងពួង។ ពួកគេនិយាយថា សាសនាទាំងឡាយរារាំងដំណើរការលូតលាស់របស់មនុស្សជាតិ ហើយដឹកនាំមនុស្សក្នុងផ្លូវខុស ដោយណែនាំនូវជំនឿ និងការប្រតិបត្តិជាអរូបី គួរឱ្យអស់សំណើច ហើយនឹងព្យាយាមហាមឃាត់មនុស្សឱ្យឃ្លាតឆ្ងាយពីព្រឹត្តិការណ៍ដែលរកឃើញដោយអ្នកវិទ្យាសាស្ត្រ។ ប៉ុន្តែ ពេលយើងពិនិត្យបញ្ជាក់នូវរបៀបដែលពួកគេបានពន្យល់នូវអត្ថន័យនៃពាក្យសាសនា យើងអាចយល់បានថា ពុទ្ធសាសនាមិនស្ថិតនៅក្នុងក្រុមសាសនាទាំងនោះទេ។

Therefore, in time to come if those intellectuals are going to oust or refute religion, it is impossible for them to throw away Buddhism as a false religion because the Buddha has revealed absolute truth. If there is truth, that will remain forever as a truth. If any truth is changeable under certain conditions, then it is not absolute truth. That is why the truth revealed by the Buddha is called noble truth. That there will remain a noble, righteous way of life which is strong enough to face any intellectual and scientific challenge.

ដូច្នេះរហូតមកដល់ពេលនេះ ប្រសិនបើបញ្ញវន្តទាំងនោះទាត់ចោល ឬបដិសេធចោលនូវសាសនាទាំងឡាយ វាក៏នៅតែមិនអាចទៅរួចទេ សម្រាប់ពួកគេក្នុងការគ្រវែងចោលនូវពុទ្ធសាសនា ដូចជាសាសនា (គ្មានសច្ចភាព) ទាំងនោះ ព្រោះថា ព្រះសម្មាសម្ពុទ្ធបានបង្ហាញឱ្យឃើញនូវបរមត្ថសច្ចៈយ៉ាងច្បាស់ឥតខ្ចោះ ។ ប្រសិនបើមានសច្ចភាពមែន សច្ចភាពនោះនឹងនៅតែជាសច្ចភាពរៀងរហូតអញ្ចឹង ។ បើសច្ចភាពណាមួយអាចប្រែប្រួល ក្រោមល័ក្ខខ័ណ្ឌណាមួយ ដូច្នេះវាមិនមែនជាសច្ចភាពពិតប្រាកដឡើយ ។ នោះជាមូលហេតុដែលសច្ចភាពបានសំដែង ដោយព្រះសម្មាសម្ពុទ្ធត្រូវបានគេហៅថា " អរិយសច្ចៈ" ។ សច្ចភាពនោះ បានដឹកនាំមនុស្សឱ្យក្លាយទៅជាអរិយបុគ្គល ។ ដូច្នេះនៅមានព្រះធម៌ដែលមាំទាំក្នុងការប្រឈមមុខ នឹងការប្រកួតប្រជែងនៃវិទ្យាសាស្ត្រ និងបញ្ញវន្តទាំងឡាយទាំងពួង ។

In that respect the Buddha’s message is unshakeable. Intellectuals surely give due respect to this way of life if they really can understand what the Buddha taught

ស្ថិតក្នុងល័ក្ខខ័ណ្ឌបែបនេះ ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធមិនអាចកែប្រែបានឡើយ ។ បញ្ញវន្តទាំងឡាយពិតជានឹងគោរពចំពោះមាគ៌ាជីវិតនោះ បើពួកគេពិតជាអាចយល់នូវអ្វីដែលព្រះសម្មាសម្ពុទ្ធបានសំដែង ។

Therefore, the teachings of the Buddha will continue to be a way of life, continue to aspire for a noble, holy and perfect life, a life of peace and happiness whether religions labels exist or not.

ដូច្នេះពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង នឹងនៅតែបន្តជាមាគ៌ាជីវិតរៀងរហូត សម្រាប់ជីវិតដ៏ប្រសើរ បរិសុទ្ធ និងថ្លៃថ្លា ជាជីវិតសន្តិភាព និងសុខសុភមង្គល ទោះបីពាហិរសាសនាមាន ឬ មិនមាន ក៏ដោយ ។

## A LIBERAL RELIGION
## សាសនាប្រណី

Another important point that the Buddha has taught us is how to live, work and co-operate with the followers of other co-religionists without disturbing them while practising our own religion. This type of liberal religion is very important if we are to live peacefully without religious prejudices and conflicts. The Buddha’s peace message of tolerance is remarkable. It is a great virtue and is useful for peaceful co-existence in any country with any race at any time.

ចំណុចសំខាន់មួយទៀត ដែលព្រះសម្មាសម្ពុទ្ធបានបង្រៀនយើងទាំងអស់គ្នា គឺរបៀបរស់នៅ ការប្រកបការងារ និងការសហប្រតិបត្តិការជាមួយបរិស័ទនៃសាសនាផ្សេងៗទៀត ដោយមិនជ្រៀតជ្រែករំខានពួកគេ ខណៈពេលប្រតិបត្តិសាសនារបស់យើង ។ ប្រភេទនៃសាសនាសេរីនិយមនេះ គឺមានសារៈសំខាន់ណាស់ ប្រសិនបើយើងចង់រស់នៅប្រកបដោយសន្តិភាព គ្មានការប្រកាន់សាសនា និងគ្មានការប៉ះទង្គិចគ្នា ។ ទស្សនៈសន្តិភាពនៃការអត់ធ្មត់របស់ព្រះសម្មាសម្ពុទ្ធគួរឱ្យកត់សំគាល់បំផុត ។ វាគឺជាអធិសីល និងមានប្រយោជន៍សម្រាប់ការរួមរស់ជាមួយគ្នា ទោះស្ថិតនៅក្នុងប្រទេសណា មានជាតិសាសន៍ជាអ្វី ក្នុងពេលណាៗក៏ដោយ ។

## A FREE RELIGION
## សាសនាសេរីភាពនិយម

The freedom that the followers of the Buddha enjoy in this world is commendable. In fact, many Buddhists have not yet realised this. We have full freedom to judge and to think, either to accept or to reject anything.

សេរីភាព ដែលពុទ្ធសាសនិកទាំងឡាយពេញចិត្តពេញថ្លើមនៅក្នុងលោកនេះ គឺគួរឱ្យសរសើរ ។ តាមពិតពុទ្ធសាសនិកភាគច្រើនមិនទាន់បានដឹង ឬស្គាល់នូវសេរីភាពនេះនៅឡើយទេ។ យើងមានសេរីភាពពេញលេញក្នុងការសម្រេចចិត្ត ក្នុងការគិត ថែមទាំងក្នុងការទទួលយក ឬបដិសេធចោលនូវអ្វីគ្រប់យ៉ាងដែលមិនពេញចិត្ត ។

We are not bound to accept anything in the name of religion either simply by thinking of the greatness of the religious teacher or by thinking that it is our duty to accept just because those teachings are found in our holy scripture or because they are our traditions or customs. Buddhists are at liberty to investigate and to accept if agreeable with their own conviction.

យើងមិនចាំបាច់ធ្វេចភ្នែកទទួលយកនូវអ្វីក្នុងនាមនៃសាសនា ជារួមទៅសូម្បីដោយការគិតរបស់មេសាសនាធំៗ ឬការគិតថា វាជាកាតព្វកិច្ចរបស់យើងក្នុងការទទួលយក ព្រោះទ្រឹស្តីទាំងនោះ ត្រូវបានគេរកឃើញនៅក្នុងគម្ពីររបស់យើង ឬថា វាជាប្រពៃណីទំនៀមទំលាប់របស់យើងនោះទេ។ ពុទ្ធសាសនិកមានសេរីភាពក្នុងការតាមដាន និងការទទួលយក ប្រសិនបើអាចសមស្របនឹងជំនឿផ្ទាល់របស់ផងខ្លួន ។

Buddhists do not accept or reject anything without any sensible reasons. They never say that they are forbidden to do this or that. They say that they do not like to do this because it creates some troubles or miseries or pains or disturbance amongst the masses. They do certain good deeds not because Buddhism asks them to do so but because they realise the value and meaning of such good practices for the welfare of others.

ពុទ្ធបរិស័ទទាំងឡាយមិនចេះតែទទួលយក ឬបដិសេធចោលនូវអ្វីៗ ដោយគ្មានហេតុផលទេ ។ គេមិនដែលនិយាយថា គេត្រូវបានហាមឃាត់មិនឱ្យធ្វើនេះ ឬធ្វើនោះឡើយ។ គេមានតែនិយាយថា គេមិនចូលចិត្តធ្វើវត្ថុនេះ ព្រោះវាធ្វើឱ្យមានបញ្ហាខ្វល់ខ្វាយក្រហាយទឹក ឈឺចុកចាប់ ឬចលាចលក្នុងចំណោមមហាជនទាំងឡាយ ។ ពួកគេធ្វើនូវអំពើល្អពិតៗ មិនមែនព្រោះតែពុទ្ធសាសនាអង្វរករពួកគេឱ្យធ្វើនោះទេ ប៉ុន្តែព្រោះតែពួកគេយល់ច្បាស់នូវគុណតំលៃ និងអត្ថន័យខ្លឹមសារពិតនៃការធ្វើនូវអំពើល្អនោះ ដើម្បីសុខសន្តិភាពដល់សង្គម ។

This is a religion of freedom which never restricts the personal affairs of man if they are not immoral or harmful. Buddhists have full freedom to organise their family affairs without violating the basic religious principles. This religion is like a gold mine to intellectuals to do some research work and to find out the deeper aspect of psychology, philosophy, science and the universal law, for the spiritual development and for the liberation of mankind from unsatisfactoriness and unrest.

នេះគឺជាសាសនានៃសេរីភាព ដែលមិនបានដាក់កំណត់លើកិច្ចការផ្ទាល់ខ្លួនរបស់មនុស្សលោក ប្រសិនបើពួកគេមានសីលធមិ ឬមិនបៀតបៀនគ្នា។ ពុទ្ធបរិស័ទមានសេរីភាពពេញលេញ ក្នុងការរៀបចំចាត់ចែងកិច្ចការចិញ្ចឹមគ្រួសាររបស់ខ្លួន ដោយមិនបំពារបំពានលើគោលការណ៍ទាំងឡាយរបស់សាសនា។ សាសនានេះគឺដូចជារ៉ែមាសចំពោះបញ្ញវន្តទាំងពួង ដើម្បីធ្វើការស្រាវជ្រាវ និងឈ្វេងយល់នូវលក្ខណៈដ៏ជ្រាលជ្រៅនៃចិត្តវិទ្យា ទស្សនវិទ្យា វិទ្យាសាស្ត្រ និងច្បាប់សាកល ឬច្បាប់កម្មផល សម្រាប់ការហ្វឹកហ្វឺនអប់រំផ្លូវចិត្ត និងសម្រាប់ការរំដោះមនុស្សជាតិឱ្យផុតពីសេចក្តីទុក្ខទាំងពួង និងកោលាហលផ្សេងៗ។

That is why for more than 2500 years, Buddhism could manage to convince the masses in almost every Asian country. At that time people invited and welcomed the Buddha’s teachings as a peace message or a goodwill message. That is why Buddhists have introduced this religion without any difficulty, without adopting any kind of exploitation.

ហេតុដូច្នេះហើយបានជាអស់រយៈពេលជាង ២៥០០ ឆ្នាំកន្លងមកនេះ ពុទ្ធសាសនាអាចធ្វើឱ្យមហាជនមានជំនឿទុកចិត្ត ដោយច្រើនបំផុតគ្រប់ប្រទេសនៅអាស៊ីអាគ្នេយ៍។ នៅពេលនោះមនុស្សទាំងឡាយបានសិក្សា និង

ស្វាគមន៍ ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាទ្រឹស្តីសន្តិភាព អហិង្សា។ នោះក៏ជាហេតុដែលពុទ្ធសាសនិកទាំងឡាយ ផ្សព្វផ្សាយសាសនានេះ ដោយគ្មានភាពលំបាក ដោយគ្មានការចាប់ជញ្ជក់យកផលប្រយោជន៍ណាមួយឡើយ ។

## BUDDHA PREACHED THROUGH HIS OWN EXPERIENCE
## ព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មានមនុស្សសត្វតាមរយៈបទពិសោធន៍ផ្ទាល់របស់ព្រះអង្គ

This is the only religion which explained to mankind through experience, realisation, wisdom and enlightenment of the founder of this religion without introducing it as a message given by  a god.

នេះគឺជាសាសនាតែមួយគត់ដែលបានពន្យល់មនុស្សជាតិ ឆ្លងតាមបទពិសោធន៍ ការឃើញពិត បញ្ញា និង ការត្រាស់ដឹងរបស់អ្នកបង្កើតសាសនានេះ ដោយមិនមានការណែនាំពន្យល់ថា វាជាទ្រឹស្តីដែលត្រូវបានឱ្យដោយព្រះ-អាទិទេពឡើយ ។

Human problems must be understood by human being through human experience by developing great humane virtues and should find out the solution to settle these problems by a human being through the purification and development of that human mind, and not through outsiders. That is why the Buddha did not introduce Himself as a supernatural saviour. He did not acknowledge that there is such a saviour. According to Him we are the only saviours to save ourselves.

បញ្ហារបស់មនុស្សប្រាកដជាត្រូវយល់ដោយមនុស្ស តាមរយៈបទពិសោធន៍របស់មនុស្ស ដោយចម្រើនធម៌មនុស្សដ៏ប្រសើរ ហើយគួរតែស្វែងរកដំណោះស្រាយបញ្ហាទាំងនេះដោយមនុស្ស ឆ្លងតាមការធ្វើចិត្ត មនុស្សនោះឱ្យស្អាតបរិសុទ្ធ និងការចម្រើនអប់រំចិត្តមនុស្ស មិនមែនតាមរយៈអ្នកខាងក្រៅទេ ។ នោះជាហេតុ ដែលព្រះអង្គមិនបានណែ-នាំខ្លួនព្រះអង្គដូចជាព្រះអាទិទេព ។ ព្រះពុទ្ធមិនកត់សំគាល់ឃើញអ្នកជួយបែបហ្នឹងសោះឡើយ ។ តាមរយៈព្រះអង្គ យើងគឺជាអ្នកជួយសង្គ្រោះខ្លួនយើង ឬខ្លួនឯងជាទីពឹងរបស់ខ្លួនឯង ។

## THREE CHARACTERISTICS
## ត្រៃលក្ខណ៍

The three essential characteristics of everything in this universe is clearly explained only in this religion. They are : impermanency of everything, unsatisfactories of everything and the impersonality or unsubstantiality of everything. This is the most remarkable discovery of the Buddha. But due to ignorance of mankind, very few can understand this kind of lofty and sublime teaching.

លក្ខណៈដ៏សំខាន់បីយ៉ាងនៃវត្ថុគ្រប់យ៉ាងក្នុងលោក ត្រូវបានពន្យល់តែក្នុងពុទ្ធសាសនាប៉ុណ្ណោះ ។ លក្ខណៈទាំងបីនោះគឺ អនិច្ចំ ទុក្ខំ និងអនត្តា ។ នេះគឺជាការស្រាវជ្រាវរាវរកដ៏គួរឱ្យកត់សំគាល់បំផុតរបស់ព្រះសម្មាសម្ពុទ្ធ។ ប៉ុន្តែដោយសារភាពអវិជ្ជារបស់មនុស្ស ទើបមានមនុស្សតិចតួចអាចយល់នូវប្រភេទពាក្យប្រៀនប្រដៅដ៏ត្រចះត្រចង់ឧត្តុង្គឧត្តមនេះ ។

## CAUSE OF OUR PROBLEMS

## ហេតុនៃបញ្ហារបស់យើង

Another important aspect of this religion is the explanation of the main cause of human problems and sufferings. According to the Buddha, we are facing all these problems in this mundane world due to our strong craving which exists in our mind. He has revealed that there are three kinds of craving forces in our minds and these are responsible for our existence, rebirth and all the other thousands of problems and mental disturbances. They are craving for existence, craving for worldly or sensual indulgence and craving for non-existence. To understand the real meaning of this interpretation of the Buddha, we have to think about this very carefully and wisely until realisation comes to us.

លក្ខណៈសំខាន់មួយទៀតនៃសាសនានេះគឺ សេចក្តីពន្យល់នៃមូលហេតុចម្បងនៃបញ្ហាមនុស្ស និងសេចក្តីទុក្ខទាំងពួង។ ផ្អែកតាមព្រះសម្មាសម្ពុទ្ធជាម្ចាស់ថា យើងកំពុងប្រឈមមុខនឹងបញ្ហាគ្រប់ជំពូកនៅក្នុងលោកីយ៍នេះ ដោយសារតែចំណង់តណ្ហា ការលោភលន់ហួសប្រមាណដែលមាននៅក្នុងចិត្តរបស់យើង។ ព្រះអង្គបានសំដែងថា មានតណ្ហាដ៏មានកំលាំងបីយ៉ាងក្នុងចិត្តរបស់យើង ហើយតណ្ហាទាំងនេះគឺជាអ្នកនាំឱ្យមានភព នាំឱ្យមានកំនើត បញ្ហាផ្សេងៗទៀតរាប់ពាន់ និងចលាចលផ្លូវចិត្តរាប់ជំពូក។ តណ្ហាទាំងនោះគឺ **កាមតណ្ហា** ***ភវតណ្ហា*** និង***វិភវតណ្ហា*** ។ ដើម្បីយល់នូវអត្ថន័យពិតនៃសេចក្តីពន្យល់របស់ព្រះសម្មាសម្ពុទ្ធ យើងត្រូវតែគិតដោយប្រុងប្រយ័ត្នបំផុត និងប្រកបដោយបញ្ញា រហូតដល់ការយល់ជាក់ច្បាស់កើតឡើងដល់យើង ទើបប្រសើរ។

World famous philosophers and psychologists also have explained the same three forces in different languages as causes of existence. Arthur Schophenhaur explains these three forces as sexuality, self preservation and suicide. Psychologists like Sigmond Freud explain the same things as libido, ego instinct and death instinct.

ទស្សនវិទូ និងអ្នកចិត្តវិទ្យាល្បីៗពិភពលោក ក៏បានពន្យល់នូវឥទ្ធិពលតណ្ហាទាំងបីដូចគ្នា ជាភាសាផ្សេងៗថា ជាមូលហេតុនៃភពកំណើត ។ លោកអាធឺ ***ស្កុបហ៊ិនហូ*** (Arthur Schophenhaur) ពន្យល់នូវលក្ខណៈទាំងបីថា ជាការមានភេទសម្ព័ន្ធ ការការពារខ្លួន (ការថែរក្សាខ្លួន) និងការធ្វើអត្តឃាត ។ អ្នកចិត្តវិទ្យាទាំងឡាយ ដូចជាលោកស៊ិគម៉ុន ហ្វ្រូត (Sigmond Freud) បានពន្យល់រឿងនេះដូចគ្នាថា ជាកាមតម្រេក ការជាប់ចិត្តនៃរូប និងសេចក្តីស្លាប់ ។

Another psychologist, Carl Jung says: “From the sources of instinct spring forth everything creative”. This is the way great intellectuals are prepared to support the truth revealed by the Buddha twenty-five centuries ago. However, when we examine these explanations, we can understand that Buddha has gone beyond the understanding capacity of other great thinkers regarding these issues.

អ្នកចិត្តវិទ្យាមួយទៀតឈ្មោះលោក ***ខាល ជុង*** (Carl Jung) និយាយថា ព្រោះតែតណ្ហានាំឱ្យអ្វីៗកើតឡើង។ នេះគឺជាទស្សនៈដែលបញ្ញវន្តល្បីៗទាំងឡាយរៀបចំ ក្នុងការទទួលយកនូវសច្ចភាពដែលសំដែងដោយព្រះសម្មាសម្ពុទ្ធអស់រយៈកាល ២៥ សតវត្សរកន្លងទៅហើយនោះ ។ ទោះបីយ៉ាងណា នៅពេលយើងសង្កេតពិនិត្យនូវសេចក្តីពន្យល់ទាំងនេះ យើងអាចយល់បានថា ព្រះសម្មាសម្ពុទ្ធមានព្រះបញ្ញាញាណ ខ្ពស់ហួសពីសមត្ថភាពយល់ដឹងរបស់ទស្សនវិទូល្បីៗទៅទៀត ទាក់ទិននឹងបញ្ហានេះ ។

## CAUSE OF SUFFERINGS

## ហេតុនាំឱ្យកើតទុក្ខ

Evidently the world is full of various kinds of sufferings such as death, decay, sorrow lamentation, pain, despair etc. The Buddha pointed out that birth (Jati) brings forth sufferings. If there is no birth, there is no scope for suffering.

តាមពិតពិភពលោក គឺពោរពេញទៅដោយសេចក្ដីទុក្ខគ្រប់ជំពូក មានដូចជាសេចក្ដីស្លាប់ ការចាស់ជរា ការសោក-សៅ ការខ្សឹកខ្សួល ការឈឺចុកចាប់ ការអស់សង្ឃឹម ។ល។ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា ការកើត នាំឱ្យកើតទុក្ខ ។ ប្រសិនបើគ្មានការកើត ក៏គ្មានសេចក្ដីទុក្ខដែរ ។

Q: Why is there birth?

តើហេតុអ្វីបានជាមានការកើត?

A: The sub-conscious process of becoming as a combination of mind and body (Nama-rupa) (bhava) causes birth. In other words, where there is bhava, there is birth.

ដំណើរការនៃការកើត ជាការរួមបញ្ចូលគ្នានូវ**នាម** និង**រូប** បានជាភពផ្ដល់កំណើត។ ន័យមួយទៀតថា ទីណាមានភព ទីនោះមានការកើត។

Q: What leads to the formation of the combination of body and mind?

តើអ្វីនាំឱ្យមាន**នាម** និង**រូប** ?

A: Thoughts grasped by Tanha (upadana lead to the formation of Karmic tendencies and lead to mind-body combination).

ចិត្តដែលជាប់ដោយ **តណ្ហាឧបាទាន** នាំឱ្យកើត**សង្ខារ** ហើយ**សង្ខារ** ទាំងឡាយនាំឱ្យកើត**នាម** និង**រូប** ។

Q: What leads to clinging?

តើអ្វីនាំឱ្យកើត**ឧបាទាន**?

A: Craving (tanha) leads to clinging.

**តណ្ហា**នាំឱ្យកើត**ឧបាទាន** ។

Q: What produces craving?

តើអ្វីនាំឱ្យកើត**តណ្ហា**?

A: Craving is produced by sensations or feeling (Vedana).

**តណ្ហា**ត្រូវបានបង្កើតឡើងដោយ**វេទនា** ។

Q: What generates feeling?

តើអ្វីបង្កើត**វេទនា**?

A: It is the contact ( of the senses with their objects) which generates feeling.

វាគឺ**ផស្សៈ**ជាអ្នកបង្កើត**វេទនា** ។

Q: Why is there such contact?

អញ្ចឹង តើហេតុអ្វីបានជាមាន**ផស្សៈ** ?

A: Six sense-bases (salayatana) are the causes of contact.

**សឡាយតនៈ**ទាំង៦ គឺជាមូលហេតុនាំឱ្យកើត**ផស្សៈ** ។

Q: How do the six sense-bases come into being?

តើ**សឡាយតនៈ**ទាំង៦ កើតឡើងដូចម្ដេច?

A: Psycho-physical combination (namarupa) brings forth six sense-bases.

ការបូកបញ្ចូលគ្នានូវ**នាម** និង**រូប** នាំឱ្យកើត**សឡាយតនៈ** ។

Q: How does the psycho-physical combinations come into being?

តើ**នាម** និង**រូប**កើតឡើងដូចម្តេច?

A: With the appearance of inactive or passive consciousness (vinnana or vipaka citta) psycho-physical combination comes into being.

**នាម** និង**រូប**កើតឡើងដោយសារ**វិញ្ញាណ** ឬ**វិបាកចិត្ត**។

Q: How does there appear passive consciousness?

តើ**វិបាកចិត្ត**កើតឡើងដូចម្តេច ?

A: It is the outcome of karmic energies (sankhara).

វាគឺជាផលរបស់**កម្ម** (**សង្ខារ**) ។

Q: How do karmic energies ( sankhara) appear?

តើ**សង្ខារ**ទាំងឡាយកើតឡើងដូចម្តេច?

A: In dependence upon ignorance (avjja) which is a facet of Tanha Karmic energies appear.

**សង្ខារ**ទាំងឡាយកើតមានព្រោះ**អវិជ្ជា** ពោលគឺសេចក្តីល្ងង់ខ្លៅ ។

Thus it is apparent that ignorance (avijja) is at the whole process. However, it cannot be taken as a beginning of "prima causal", a meta-physical cause or a cosmogenic principle, but as a condition under which development takes place. In dependence upon the one another they arise. In fact this is a conditional arising "paticca-samuppada". The entire series can be called as the cycle of existence " bhava cakka". Every link can be combined with another. These links (i.e. ignorance. Karmic energies etc) are known as the twelve spokes of the wheel of existence.

ដូចនេះវាច្បាស់ហើយថា អវិជ្ជាគឺនាំឱ្យកើតសង្ខារទាំងពួង ។ ទោះបីយ៉ាងណា គេមិនអាចត្រូវទទួលយកថា ជាការចាប់ផ្តើមហេតុនៃបរមត្ថវិជ្ជា ឬក៏គោលការណ៍បង្កើតលោកទេ តែថាវាជាបច្ច័យដល់ការចម្រើនលូតលាស់ជំនួសវិញ ។ ពួកធម៌ទាំងនេះ កើតឡើងដោយពឹងផ្អែកគ្នាពីមួយទៅមួយ ។ អ្វីដែលមានត១គ្នារហូត ត្រូវបានគេហៅថា "ចក្រភព" ឬ "ភវចក្ក"។ តាមពិតនេះគឺជាការកើតឡើងនៃបច្ច័យ (បដិច្ចសមុប្បាទ)។ គ្រប់បដិសន្ធិ គឺត្រូវភ្ជាប់ទៅនឹងវត្ថុផ្សេងទៀត ។ ខ្សែបដិសន្ធិទាំងនេះ (អវិជ្ជា, សង្ខារ ។ល។) ត្រូវបានគេស្គាល់ថា ជាកាំ (កង ឬអង្គ) ទាំង ១២ នៃភវចក្រ។

These spokes are linked with the past, present and future in succession. In the background of past life, ignorance and karmic energies are found. With the sphere of present life there are reactive types of consciousness, psycho-physical combination, six sense-bases, contact, sensation, craving, clinging, formation of karmic tendencies. In the future are seen the rebirth and attendant sufferings. Thus the cycle of existence being linked with the period of past, present and future goes on.

កាំទាំងនេះជាប់ទាក់ទងជាមួយបច្ចុប្បន្ន អតីត និងអនាគត បន្តបន្ទាប់គ្នាហូរហែ។ កាលពីអតីតជាតិ អវិជ្ជា និងសង្ខារ ត្រូវបានគេរកឃើញ។ ដល់មកបច្ចុប្បន្នជាតិនេះ ក៏មានការប្រទះឃើញនៃវិញ្ញាណ នាម និងរូប អាយតនៈទាំង ៦ ផស្សៈ វេទនា តណ្ហា ឧបាទាន និងសង្ខារទៀត ។ លុះពេលអនាគតជាតិ ត្រូវបានឃើញមានការកើត និងសេចក្តីទុក្ខនេះដដែល។ ដូចនេះ សង្សារវដ្តនេះត្រូវបានចងភ្ជាប់ជាមួយអតីត បច្ចុប្បន្ន និងអនាគត ត១គ្នា។

This is a religion in which we can find real religious principles, which can be maintained without changing the same basic ideas and principles at any time, anywhere, and under any circumstances. The understanding capacity of the value of these religious ideas may disappear from the man's mind. Man may experienced the difficulty of practising these principles in a corrupted society. But the value of this precious golden discipline will be appreciated by every cultured and understanding man at anytime.

នេះជាសាសនា ដែលយើងអាចស្រាវជ្រាវរកឃើញគោលការណ៍ពិត ដែលអាចនៅស្ថិតស្ថេរ គ្មានការផ្លាស់ប្តូរ គំនិត និងគោលការណ៍គ្រឹះ ដូចគ្នានៅគ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់កាលៈទេសៈ ។ លទ្ធភាព យល់ដឹងនូវតំលៃនៃទស្សនៈសាសនាទាំងនេះ អាចសាបរលត់ពីចិត្តមនុស្ស។ មនុស្សច្បាស់ជាជួបប្រទះផលលំបាកក្នុងការអនុវត្តទ្រឹស្តីទាំងនេះ នៅក្នុងសង្គមអ័ព្ទអួ។ ប៉ុន្តែគុណតំលៃនៃសំដីមាសរបស់សាសនានេះ នឹងត្រូវបានឱ្យតំលៃដោយមនុស្សដែលមានវប្បធម៌ និងបញ្ញា នៅពេលណាមួយមិនខានឡើយ។

It is hoped that the explanation given here would serve as an appropriate answer to the question “ Why Buddhism?” and as to why Buddhism needed even in this modern era.

ខ្ញុំសង្ឃឹមថា សេចក្តីពន្យល់ប៉ុណ្ណេះអាចចាត់ទុកជាចម្លើយសមល្មមនឹងសំនួរថា "ហេតុអ្វីបានជាមានពុទ្ធសាសនា?" ក៏ដូចជាសំនួរថា ហេតុអ្វីចាំបាច់ត្រូវការពុទ្ធសាសនា? បើសង្គមគេជឿនលឿនហើយនោះ

**ពុទ្ធសាសនំ ចិរំ តិដ្ឋតុ!**

Buddha Sasanam Ciram Titthatu!

**ចប់ដោយបរិបូរណ៍**

THE END